សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការឃុំខ្លួនបណ្ដោះអាសន្ន នៃដំណាក់កាល ចៅក្រមស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២៤


| ស្រាវជ្រាវដោយ | ណែនាំដោយ |
|---|---|
| និស្សិតឈ្មោះ **លោក សឿន ពិសិដ្ឋ** | លោក **ឃួយ កុសល** |
| **លោក ឆន់ ច័ន្ទតារាស្មី** | |



| | |
|---|---|
| ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា **២០២០** |
| ជំនាន់ទី **២៤** | ឆ្នាំសរសេរសារណា **២០២៤** |

# សេចក្តីថ្លែងអំណរគុណ


យើងខ្ញុំទាំងពីររូបឈ្មោះ **សឿន ពិសិដ្ឋ** និង **ធន់ ច័ន្ទតារារស្មី** ជានិស្សិតបរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត ក្រុម L4C3 ជំនាន់ទី២៤ ក្នុងឆ្នាំសិក្សា ២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

**យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរគុណ និងសម្តែងនូវកតញ្ញូធម៌ការដឹងគុណចំពោះ**

លោកឪពុកឈ្មោះ **ខា សាត**, អ្នកម្តាយឈ្មោះ **ចាន់ ឥន្ទី** និងលោកឪពុកឈ្មោះ **ធន់ ច័ន្ទតារា** និងអ្នកម្តាយឈ្មោះ **ឈូ ម៉ុនណារី** ដែលលោកមានគុណយ៉ាងធំធេងលើសលប់មិនអាចកាត់ថ្លៃបាន ដែលមានព្រហ្មវិហារធម៌ទាំងបួនដល់កូនៗ ព្រោះលោកទាំងពីរបានផ្តល់កំណើត និងការចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មានប្រៀនប្រដៅដាស់តឿនកូនៗឱ្យប្រព្រឹត្តតែអំពើល្អ សេពគប់មិត្តភក្តិល្អៗជាដើម។ ការលះបង់ទាំងកម្លាំងកាយចិត្ត និងថវិកាដល់កូនបានរៀនសូត្រ ចំណេះដឹងរហូតចប់បរិញ្ញាបត្រដោយជោគជ័យ។

យើងខ្ញុំទាំងពីររូបសូមថ្លែងអំណរអរគុណចំពោះ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្រៀន យកចិត្តទុកដាក់ដោយទំនួលខុសត្រូវខ្ពស់ក្នុងការអប់រំទូន្មាននឹងផ្តល់នូវចំណេះដឹង ការដាស់តឿនឱ្យនិស្សិត ខិតខំសិក្សា ស្វែងរកចំណេះដឹងដាក់ខ្លួន។

ជាពិសេសនោះ យើងខ្ញុំទាំងពីររូប ក៏សូមធ្វើការថ្លែងអំណរគុណ និងការដឹងគុណយ៉ាងជ្រាលជ្រៅទៅកាន់លោកគ្រូ **ឃួយ កុសល** ដែលជាសាស្រ្តចារ្យណែនាំលើប្រធានបទរបស់យើងខ្ញុំទាំងពីររូប ទោះបីជាមានការនឿយហត់ និងលំបាកខ្លះ ក៏លោកនៅតែជួយជ្រោមជ្រែង ផ្តល់នូវទ្រឹស្តី របៀបនៃការសិក្សាស្រាវជ្រាវ បទពិសោធន៍ល្អៗ ការផ្តល់ដំបូន្មានមតិយោបល់ និងជួយកែសម្រួលខ្លឹមសារ ដែលពួកយើងខ្ញុំសរសេរឱ្យក្លាយជាសៀវភៅមួយក្បាលប្រកបដោយអត្ថន័យ និងខ្លឹមសារអាចទទួលយកបាន។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ សូមជូនពរឱ្យ លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តនិស្សិត និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបម្រើការងារនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ មានតែសុខភាពល្អ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងសូមឱ្យសមប្រកប និងជួបប្រទះនៅពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តជំនាន់ទី២៤ សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០២០-២០២៤។ ក្នុងឱកាសដ៏មានតម្លៃនេះដែលសាកលវិទ្យាល័យផ្ដល់ឱ្យយើងខ្ញុំទាំងពីរបានសម្រេចចិត្តជ្រើសរើស និងរៀបចំស្រាវជ្រាវតាក់តែងនូវសារណាមួយនេះក្រោមប្រធានបទ ស្ដីអំពី "**ការឃុំខ្លួនបណ្ដោះអាសន្ន នៃដំណាក់កាលចៅក្រមស៊ើបសួរ**" ដែលបានកើតចេញពីការខិតខំសិក្សាស្រាវជ្រាវនាពេលកន្លងមកនេះ។

ការសិក្សាស្រាវជ្រាវ នូវប្រធានបទខាងលើនេះ ក្នុងគោលបំណងដើម្បីស្វែងយល់ដឹងឱ្យកាន់តែស៊ីជម្រៅអំពីដំណើរការនៃការឃុំខ្លួនបណ្ដោះអាសន្នដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ តាំងពីពេលដែលចៅក្រមស៊ើបសួរបានទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និង/ឬ តាមរយៈការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប្ដឹងមកចៅក្រមស៊ើបសួរ រហូតដល់បញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្នក្នុងដំណាក់កាលស៊ើបសួរ។

យើងខ្ញុំពិតជាមានមោទនភាពយ៉ាងខ្លាំងចំពោះស្នាដៃមួយនេះ ដោយហេតុថាការស្រាវជ្រាវមួយដែលកើតចេញពីការខិតខំប្រឹងប្រែង តស៊ូព្យាយាមសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់បំផុត ក្នុងការសម្រិតសម្រាំងចម្រាញ់យកខ្លឹមសារដែលមាននូវគុណភាព និងសារៈសំខាន់ដើម្បីយកមកចងក្រងជាសារណានេះឡើង ហើយការស្រាវជ្រាវនេះទៀតសោត គឺជាលក្ខខណ្ឌមួយក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រប្រកបដោយជោគជ័យ។ ការសិក្សាស្រាវជ្រាវនេះ គឺបានបន្សល់ទុកជាស្នាដៃមួយដើម្បីជាប្រយោជន៍ដល់បងប្អូន សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវគ្រប់ជំនាន់ឱ្យបានដឹង និងស្វែងយល់ រួមទាំងជាជំនួយការពង្រីកចំណេះដឹងបន្ថែមនៃប្រធានបទខាងលើនេះ។ ទោះបីជាយ៉ាងណាយើងខ្ញុំទាំងពីររូប ជឿជាក់ថាសារណាមួយនេះ ក៏មាននៅភាពខ្វះខាតចន្លោះប្រហោង ដែលមិនទាន់គ្រប់ជ្រុងជ្រោយ និងល្អឥតខ្ចោះនៅឡើយទេ ប៉ុន្តែយើងខ្ញុំទាំងពីររូបសង្ឃឹមថាបងប្អូន សិស្សនិស្សិត អ្នកសិក្សាស្រាវជ្រាវគ្រប់ជំនាន់ នឹងមានការយោគយល់អធ្យាស្រ័យនូវរាល់កំហុសឆ្គងដែលកើតមានឡើង ហើយយើងខ្ញុំទាំងពីររូបនៅរង់ចាំទទួលរាល់ការរិះគន់ទាំងអស់ក្នុងន័យស្ថាបនាពីសំណាក់សាស្រ្តាចារ្យ បងប្អូនសិស្ស និស្សិត និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដោយក្ដីរីករាយ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីររូបសូមឱនលំទោនកាយគោរពជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្រ្តាចារ្យ និងបងប្អូនដែលជា សិស្សនិស្សិត អ្នកសិក្សាស្រាវទាំងអស់ សូមជួបប្រទះតែសំណាងល្អ ជោគជ័យនូវរាល់ភារកិច្ចទាំងឡាយ ព្រមទាំងសូមជួបនូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

## មាតិកា

**សេចក្តីផ្តើម**......១
១. លំនាំបញ្ហានៃការស្រាវជ្រាវ......១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ......១
៣. គោលបំណងនៃការស្រាវជ្រាវ......២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ......២
៥. សារៈសំខាន់នៃការស្រាវជ្រាវ......៣
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ......៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ......៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃកិច្ចស៊ើបសួរ**

**ផ្នែកទី១ វិសាលភាពនៃការអនុវត្តរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូង**

**កថាខណ្ឌទី១ រចនាសម្ព័ន្ធ និងតួអង្គនៃដំណាក់កាលស៊ើបសួរ**
១.១. រចនាសម្ព័ន្ធស៊ើបសួរ......៤
១.២. តួអង្គក្នុងដំណាក់កាលស៊ើបសួរ......៤

**កថាខណ្ឌទី២ អំណាចរបស់ចៅក្រមស៊ើបសួរ**
២.១. ការសម្ងាត់នៃការស៊ើបសួរ......៥
២.២. សមត្ថកិច្ចនៃការស៊ើបសួរ......៦
២.៣. បើកការស៊ើបសួរ......៧

**កថាខណ្ឌទី៣ វិធានការនិរន្តរាយ**
៣.១. ដីកាបង្គាប់ឱ្យចូលខ្លួន......១០
៣.២. ដីកាបង្គាប់ឱ្យនាំខ្លួន......១១
៣.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន......១១
៣.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន......១២
៣.៥. ការអនុវត្តដីកា......១២

**ផ្នែកទី២ ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ**

**កថាខណ្ឌទី១ ការប្តឹងដោយព្រះរាជអាជ្ញា**

១.១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ........ ១៣
១.២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ........ ១៤

**កថាខណ្ឌទី២ បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

២.១. ការប្តឹងដោយដើមបណ្តឹងរដ្ឋប្បវេណី ........ ១៤
២.២. ក្រោយពីបានទទួលបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........ ១៥

## ជំពូកទី២

## ការឃុំខ្លួនបណ្តោះអាសន្ន

**ផ្នែកទី១ គោលបំណងនៃការឃុំខ្លួនបណ្តោះអាសន្ន**

**កថាខណ្ឌទី១ ទស្សនៈទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន**

១.១. គោលការណ៍ក្នុងដំណាក់កាលស៊ើបសួរ ........ ១៧
១.២. យន្តការយុត្តិធម៌ព្រហ្មទណ្ឌបែបទំនើប ........ ១៨

**កថាខណ្ឌទី២ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

២.១. លក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ២០
២.២. មូលហេតុចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន ........ ២០

**កថាខណ្ឌទី៣ នីតិវិធីនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

៣.១. បង្គាប់ឱ្យឃុំខ្លួន ........ ២២
៣.២. ការអនុវត្តជាក់ស្តែងមួយចំនួនអំពីការឃុំខ្លួនបណ្តោះអាសន្ន ........ ២២

**ផ្នែកទី២ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**

**កថាខណ្ឌទី១ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន និងអនីតិជន**

១.១. ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន ........ ២៤
១.២. ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន ........ ២៥

**កថាខណ្ឌទី២ នីតិវិធីនៃការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន**

២.១. ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ........ ២៦
២.២. ការអនុវត្តកិច្ចនៃការពន្យារពេលឃុំខ្លួន ........ ២៧

**ផ្នែកទី៣ សិទ្ធិត្រូវបានការពារ និងតំណាងដោយមេធាវី**

**កថាខណ្ឌទី១ សិទ្ធិមានមេធាវីតំណាង**

១.១. សិទ្ធិមានមេធាវី ........ ២៨
១.២. សិទ្ធិរបស់ជនត្រូវចោទជាអនីតិជន ........ ៣០

**កថាខណ្ឌទី២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌**

២.១. សិទ្ធិប្ដឹងជំទាស់ចៅក្រម ........ ៣២
២.២. សិទ្ធិត្រៀមខ្លួនគ្រប់គ្រាន់ ........ ៣៤

**ជំពូកទី៣**

**ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ**

**ផ្នែកទី១ ការដោះលែងឱ្យនៅក្រៅឃុំ**

**កថាខណ្ឌទី១ ការដោះលែងឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ**

១.១. ក្នុងករណីធម្មតា ........ ៣៦
១.២. ក្នុងករណីបន្ទាន់ ........ ៣៦

**កថាខណ្ឌទី២ ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្ដឹងសុំ**

២.១. តាមបណ្ដឹងរបស់ព្រះរាជអាជ្ញា ........ ៣៦
២.២. តាមបណ្ដឹងរបស់ជនត្រូវចោទ ........ ៣៧

**ផ្នែកទី២ ការត្រួតពិនិត្យតាមផ្លូវតុលាការ**

**កថាខណ្ឌទី១ ការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

១.១. លក្ខខណ្ឌនៃការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៨
១.២. គោលដៅនៃការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៩
១.៣. នីតិវិធីនៃការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៩

**កថាខណ្ឌទី២ បុគ្គលដែលអាចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ**

២.១. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ ........ ៣៩
២.២. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា ........ ៣៩
២.៣. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ ........ ៤០
២.៤. ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៤០

**សេចក្ដីសន្និដ្ឋាន** ............................................................ ៤១
**អនុសាសន៍** ............................................................ ៤៣
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

រដ្ឋធម្មនុញ្ញ ផ្តល់តម្លៃដល់ សិទ្ធិសេរីភាពរបស់បុគ្គល ប៉ុន្តែសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ដែលនេះជាបទប្បញ្ញត្តិដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងក្នុងគោលបំណងកំណត់អំពីវិធានទាំងឡាយនៃដំណើរការបណ្តឹងអាជ្ញាដែលត្រូវគោរព និងប្រតិបត្តិតាមដោយហ្មត់ចត់ ដើម្បីកំណត់ឱ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌ ក៏ដូចជាការការពារសិទ្ធិសេរីភាពបុគ្គល និងឱ្យជនសង្ស័យអាចជៀសផុតពីការភាន់ច្រឡំ ពោលគឺឱ្យជននោះផ្តល់នូវអំណះអំណាងបញ្ជាក់ពីសុចរិតភាពរបស់ខ្លួនផង។ ទន្ទឹមនឹងនេះ ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់នូវមធ្យោបាយមួយដល់អ្នកប្រតិបត្តិច្បាប់ ដើម្បីដាក់ទណ្ឌកម្មបទល្មើសព្រហ្មទណ្ឌឱ្យមានប្រសិទ្ធភាព ហើយដំណើរការនៃការរកឃើញពិរុទ្ធភាពរបស់ជនល្មើស គឺធ្វើឡើងដោយគ្មានមន្ទិលសង្ស័យ។ ម៉្យាងវិញទៀត ក្រមនីតិវិធីព្រហ្មទណ្ឌ មានបញ្ញត្តិនូវដំណាក់កាលជាច្រើនក្នុងរឿងក្តីព្រហ្មទណ្ឌតាំងពីដើម រហូតដល់បញ្ចប់ដែលដំណាក់កាលទាំងនេះ រួមមានដំណាក់កាលស៊ើបអង្កេតជាសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌ ដំណាក់កាលចោទប្រកាន់ជាសមត្ថកិច្ចរបស់អយ្យការ ដំណាក់កាលស៊ើបសួរជាសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ និងដំណាក់កាលជំនុំជម្រះជាសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ។

ចំពោះក្នុងដំណាក់កាលទាំង ៤ នេះ សុទ្ធតែជាដំណាក់កាលសំខាន់ ប៉ុន្តែដំណាក់កាលចៅក្រមស៊ើបសួរគឺធ្វើឡើងដើម្បីចូលរួមក្នុងការការពារផលប្រយោជន៍ ការស្វែងរកភស្តុតាង និងលក្ខខណ្ឌចាំបាច់ចៅក្រមស៊ើបសួរអាចអនុវត្តតាមការចោទប្រកាន់របស់ព្រះរាជអាជ្ញា តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលមានការចង្អុលបង្ហាញអំពីសេចក្តីសង្ខេបអង្គហេតុ ការកំណត់ឈ្មោះបទល្មើស ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស រួមទាំងឈ្មោះបុគ្គល ដែលត្រូវរងការចោទប្រកាន់មានភាពត្រឹមត្រូវ ពិតដូចដែរបានចោទប្រកាន់ក្នុងដីកា ឬអត់។ ដើម្បីជាភាពងាយស្រួលក្នុងការប្រមូលនូវភស្តុតាង និងស្វែងរកនូវការពិតចៅក្រមស៊ើបសួរ ត្រូវប្រើសិទ្ធិអំណាចដែលកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់ឱ្យគឺសិទ្ធិអំណាចក្នុងវិធានការនិរន្តរាយ ដោយចៅក្រមស៊ើបសួរ ត្រូវឃុំខ្លួនបណ្តោះអាសន្នចំពោះបុគ្គល ដែលពាក់ព័ន្ធក្នុងរយៈពេលកំណត់មួយ ដែលអនុលោមភាពតាមច្បាប់ជាធរមាន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ក្នុងរឿងព្រហ្មទណ្ឌ ការស៊ើបសួរ ជាដំណាក់កាលសំខាន់មួយនៃនីតិវិធីព្រហ្មទណ្ឌ នៅចន្លោះដំណាក់កាលនៃការផ្តើមចោទប្រកាន់ដោយអយ្យការ និងដំណាក់កាលនៃការជំនុំជម្រះ។ ការស៊ើបសួរ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ដែលចៅក្រមស៊ើសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក ហើយអាចបំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឱ្យឃើញការពិតដោយអនុលោមតាម

ច្បាប់។ នៅក្នុងចំណោមវិធានការជាច្រើន ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចដល់ចៅក្រមស៊ើបសួរ ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានមួយដែលចៅក្រមស៊ើបសួរអាច យកមកអនុវត្ត ប្រសិនបើខ្លួនយល់ឃើញថាមានប្រយោជន៍ដល់កិច្ចការនីតិវិធីស្វែងរកអត្តិភាពនៃបទល្មើស ឬការបារម្ភបាត់វត្ថុតាង។ ប៉ុន្តែការឃុំខ្លួនរបស់ចៅក្រមស៊ើបសួរ មិនមែនចេះតែសម្រេចដោយប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនហួសពីច្បាប់បានកំណត់នោះឡើយ ដែលនឹងធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់បុគ្គលដែលត្រូវការពារដោយរដ្ឋធម្មនុញ្ញ ដូចនេះការឃុំខ្លួនបណ្តោះអាសន្ន អនុវត្តយ៉ាងណាឱ្យមានប្រសិទ្ធភាព និងស្របតាមគតិច្បាប់ ព្រមទាំងផលប្រយោជន៍ជាសារវន្តរបស់ជនសង្ស័យ។

ដោយឈរលើមូលដ្ឋានទាំងនេះ ក្រុមយើងខ្ញុំបង្កើតនូវសំណួរស្រាវជ្រាវដូចខាងក្រោម ៖

១. តើការឃុំខ្លួនជនត្រូវចោទ ធ្វើឡើងដោយផ្អែកលើស្ថានភាព ឬលក្ខខណ្ឌអ្វី?

២. តើនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ប្រព្រឹត្តទៅយ៉ាងដូចម្តេច?

៣. ក្នុងករណីឃុំខ្លួនបណ្តោះអាសន្នដែលប៉ះពាល់ដល់ផលប្រយោជន៍គតិយជន តើត្រូវអនុវត្តដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីជាការឆ្លើយតបនឹងចំណោទបញ្ហាខាងលើ ក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវ និងចងក្រងជាសារណានេះឡើងក្នុងគោលបំណង ដើម្បីជាប្រយោជន៍ ក្នុងការស្វែងយល់អំពីលំហូរ នៃដំណើរការឃុំខ្លួនបណ្តោះអាសន្ន នៃដំណាក់កាលចៅក្រមស៊ើបសួរ ព្រមទាំងយល់ដឹងនូវសមត្ថកិច្ចមួយចំនួនរបស់យុត្តាធិការស៊ើបសួរផងដែរ។ បន្ថែមពីនេះ ការស្រាវជ្រាវ គឺធ្វើឡើងដើម្បីបង្ហាញពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន ឬការមិនឃុំខ្លួនជាបណ្តោះអាសន្ន ដោយហេតុថាការឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ឬការមិនឃុំខ្លួនជាបណ្តោះអាសន្ន ដែលវៀចចាកពីច្បាប់នីតិវិធីនឹងបង្កជាបញ្ហាប្រឈមមួយដ៏ធំសម្រាប់ជនរងគ្រោះ ជនត្រូវចោទ និងសណ្តាប់ធ្នាប់សង្គមទាំងមូល។ ហេតុដូចនេះហើយ បានជាក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីការមូលភាពគ្នារវាងចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញា មុននឹងចេញដីកាសម្រេចអំពីការឃុំខ្លួនជាបណ្តោះអាសន្ន ដើម្បីត្រួតពិនិត្យនូវនីតិវិធីរវាងគ្នាទៅវិញទៅមក មុនចេញដីកាសម្រេច។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះសារណាដែលក្រុមយើងខ្ញុំបានចងក្រងឡើងនេះ គឺស្ថិតនៅក្នុងដែនកំណត់នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលសិក្សាក្នុងដំណាក់កាលស៊ើបសួរ នៃសាលាដំបូង ដោយស្រាវជ្រាវចាប់ពីពេលដែលទទួលបណ្តឹង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងរបស់ព្រះរាជអាជ្ញា និង/ឬបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី រហូតដល់ការឃុំខ្លួនបណ្តោះអាសន្ន ព្រមទាំងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារណានេះ ក្រុមយើងខ្ញុំខិតខំប្រឹងប្រែងធ្វើប្រកបដោយការយកចិត្តទុកដាក់ ហើយសារណានេះ មានសារៈសំខានបំផុតសម្រាប់បងប្អូនអ្នកអាន សិស្សនិស្សិត និងអ្នកសិក្សាស្រាវជ្រាវគ្រប់ជំនាន់ ដែលមានបំណងចង់ស្វែងយល់អំពីនីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ដោយមានទាំងលក្ខខណ្ឌ មូលហេតុ រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន និងការដោះលែងឱ្យនៅក្រៅឃុំ ហើយបន្ថែមពីលើនេះទៀត ដើម្បីចូលរួមផ្សព្វផ្សាយ ព្រមទាំងលើកកម្ពស់វិស័យច្បាប់របស់ប្រទេសកម្ពុជាផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចនូវគោលបំណង នៃការស្រាវជ្រាវអត្ថបទខាងលើនេះ ក្រុមយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវទៅលើបទដ្ឋានគតិយុត្តជាតិ និងលិខិតូបករណ៍អន្តរជាតិ ដែលពាក់ព័ន្ធមួយចំនួន និងទ្រឹស្តីមេរៀនដែលធ្លាប់បានរៀនកន្លងមក ហើយក៏បានបញ្ចូលនូវខ្លឹមសារក្នុងសៀវភៅមេរៀនរបស់ លោក-លោកស្រី សាស្ត្រាចារ្យផ្សេងៗដែលមានការពាក់ព័ន្ធគ្នានឹងប្រធានបទសារណានេះផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះសារណានេះ បែងចែកជា ៣ជំពូក ដែលមានដូចតទៅ៖

### ជំពូកទី១ សញ្ញាណទូទៅនៃកិច្ចស៊ើបសួរ

- **ផ្នែកទី១ វិសាលភាពនៃការអនុវត្តរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូង**
- **ផ្នែកទី២ ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ**

### ជំពូកទី២ ការឃុំខ្លួនបណ្តោះអាសន្ន

- **ផ្នែកទី១ គោលបំណងនៃការឃុំខ្លួនបណ្តោះអាសន្ន**
- **ផ្នែកទី២ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន**
- **ផ្នែកទី៣ សិទ្ធិត្រូវបានការពារ និងតំណាងដោយមេធាវី**

### ជំពូកទី៣ ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

- **ផ្នែកទី១ ការដោះលែងឱ្យនៅក្រៅឃុំ**
- **ផ្នែកទី២ ការត្រួតពិនិត្យតាមផ្លូវតុលាការ**

# ជំពូកទី១

# សញ្ញាណទូទៅនៃកិច្ចសុីបសួរ

# ជំពូកទី១

# សញ្ញាណទូទៅនៃកិច្ចស៊ើបសួរ

## ផ្នែកទី១ វិសាលភាពនៃការអនុវត្តរបស់ចៅក្រមស៊ើបសួរនៅសាលាដំបូង

ចៅក្រមស៊ើបសួរ គឺជាដំណាក់កាលមួយនៃវិធានស្រាវជ្រាវ ដែលមានតួនាទីក្នុងស្វែងរកនូវភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចឱ្យចៅក្រមស៊ើបសួរនូវអំណាចជាច្រើន (មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ការបើកការស៊ើបសួរ ត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។ ចំពោះបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។

### កថាខណ្ឌទី១ រចនាសម្ព័ន្ធ និងតួអង្គនៃដំណាក់កាលស៊ើបសួរ

#### ១.១. រចនាសម្ព័ន្ធស៊ើបសួរ

មន្ទីរស៊ើបសួរនៃសាលាដំបូង គឺជាផ្នែកមួយនៃតុលាការព្រហ្មទណ្ឌ និងមានសមត្ថកិច្ចស៊ើបសួររឿងក្តីព្រហ្មទណ្ឌ ដោយអនុលោមតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ។ ប្រធានសាលាដំបូងត្រូវចាត់តាំងចៅក្រមយ៉ាងតិច ០២ (ពីរ) រូប តាមដីកាសម្រេចឱ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការព្រហ្មទណ្ឌនៃសាលាដំបូង ហើយដីកាសម្រេចនេះ ត្រូវកំណត់ផងដែរអំពីលំដាប់លេខរៀងសម្រាប់ការទទួលបំពេញការងារ។ ក្នុងករណីពុំមានចៅក្រមស៊ើបសួរ ឬខ្វះចៅក្រមស៊ើបសួរ ប្រធានសាលាដំបូងអាចចាត់តាំងចៅក្រមនៃតុលាការជំនាញផ្សេង ដើម្បីបំពេញមុខងារស៊ើបសួរបាន។

ចំណែកឯសាលាឧទ្ធរណ៍ ប្រធានសភាស៊ើបសួរ ត្រូវចាត់តាំងដោយប្រធានសាលាឧទ្ធរណ៍ ហើយចំនួនចៅក្រម ក្រឡាបញ្ជី និងដំណើរការរបស់សភាស៊ើបសួរ ត្រូវកំណត់ដោយប្រធានសាលាឧទ្ធរណ៍។ ចំពោះសភាស៊ើបសួរ មានសមត្ថកិច្ចដោះស្រាយលើបណ្តឹងនានាចំពោះកិច្ចស៊ើបសួរ ឬដីកាសម្រេចនានារបស់ចៅក្រមស៊ើបសួរ និងរឿងក្តីផ្សេងទៀត ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយអនុវត្តតាមបទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌជាធរមាន ហើយសេចក្តីសម្រេចសភាស៊ើបសួរត្រូវធ្វើឡើងដោយចៅក្រម០៣ (បី)រូប ដែល០១ (មួយ)រូប ជាប្រធាន។

*«ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤»*

#### ១.២. តួអង្គក្នុងដំណាក់កាលស៊ើបសួរ

តួអង្គក្នុងដំណាក់កាលស៊ើបសួរមានដូចជា ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ជនត្រូវចោទ មេធាវី និងមន្ត្រីនគរបាលយុត្តិធម៌ជាដើម។ ចំពោះចៅក្រមស៊ើបសួរ បើកការស៊ើបសួរ គឺដើម្បីស្វែងរកនូវភស្តុតាង និងពិរុទ្ធភាព សម្រាប់អង្គហេតុ ដែលចោទប្រកាន់ ឬស្វែងរកនូវធាតុចាំបាច់ សម្រាប់ធានាដល់ការចោទប្រកាន់។ ចៅក្រម

ស៊ើបសួរ អាចបើកការស៊ើបសួរបាន លុះត្រាមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា លើកលែងករណីពិសេសមួយចំនួនដែលក្រមនីតិវិធីព្រហ្មទណ្ឌបានចែង។ រីឯ ជនត្រូវចោទ គឺនៅមុនដំណាក់កាលស៊ើបសួរ មានឋានៈជាជនសង្ស័យ ប៉ុន្តែក្រោយពីព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ព្រមទាំងចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ គឺត្រូវប្តូរឋានៈពីជនសង្ស័យ ទៅជាជនត្រូវចោទវិញ។ ចំណែកមន្ត្រីនគរបាលយុត្តិធម៌ គឺនៅពេលដែលចៅក្រមស៊ើបសួរ ចេញដីកាចាត់ឱ្យស៊ើបសួរជំនួសចេញឱ្យមន្ត្រីនគរបាលយុត្តិធម៌ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រើប្រាស់សិទ្ធិអំណាចក្នុងការបំពេញកិច្ចស៊ើបសួរនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន រួមមាន កំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យ, វិធានទាក់ទងនឹងការស្តាប់ចម្លើយរបស់សាក្សី, ការឆែកឆេរ និងការចាប់យកវត្ថុតាង, ការឃាត់ខ្លួននៅក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស, ការស្តាប់ទូរស័ព្ទនៅក្នុងក្របខណ្ឌនៃដីកាចាត់ឱ្យស៊ើបសួរជំនួស និងកំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌។

### កថាខណ្ឌទី២ អំណាចរបស់ចៅក្រមស៊ើបសួរ

#### ២.១. ការសម្ងាត់នៃការស៊ើបសួរ

ការស៊ើបសួរត្រូវតែជាការសម្ងាត់ គ្រប់បុគ្គលទាំងឡាយដែលចូលរួមក្នុងការស៊ើបសួរ ជាពិសេសចៅក្រម មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ។ ទោះបីជាយ៉ាងនេះក្តី ការគោរពការសម្ងាត់វិជ្ជាជីវៈ មិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ។ ម៉្យាងទៀត ព្រះរាជអាជ្ញាអាចធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថា ព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត។ ប្រសិនបើ មានការបំពានលើការសម្ងាត់នៃការស៊ើបសួរ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។[1] ច្បាប់តម្រូវឱ្យរក្សាការសម្ងាត់ក្នុងនីតិវិធីស៊ើបសួរ ដើម្បីធានាដល់ដំណើរការរលូននៃការស៊ើបសួរ ការការពារសិទ្ធិ និងផលប្រយោជន៍ ព្រមទាំងសុខសុវត្ថិភាពរបស់ភាគី និងធានាសណ្តាប់ធ្នាប់សង្គមក្នុងពេលស៊ើបសួរ។

ទោះបីជា ច្បាប់មិនបានចែងច្បាស់តែយើងអាចយល់បានថា ការសម្ងាត់នេះត្រូវសំដៅដល់ព័ត៌មាន ឯកសារ រីដេអូ សម្ភារៈភស្តុតាងដទៃទៀតទាំងអស់ដែលមាននៅក្នុងសំណុំរឿង ដែលត្រូវចៀសវាងបញ្ចេញទិន្នន័យទាំងនេះទៅតតិយជន ដែលមិនមែនជាភាគីពាក់ព័ន្ធ។ វិធាននៃការសម្ងាត់នេះ មិនបានពន្យល់ច្បាស់អំពីទំនាក់ទំនងរវាងមេធាវីការពារក្តីជាមួយនឹង កូនក្តីរបស់ខ្លួនឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ថា មេធាវីអាចអានឯកសារនៃសំណុំរឿងឱ្យកូនក្តីរបស់ខ្លួន ដែលកំពុងជាប់នៅក្នុងពន្ធនាគារស្តាប់បាន តែមិនអាចប្រគល់ឯកសារនោះ ទៅឱ្យកូនក្តី

[1] មាត្រា ១២១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ឡើយ។ ប៉ុន្តែវិធាននេះ មិនបានកម្រិតសិទ្ធិរបស់មេធាវីខាងលើជាមួយនឹងកូនក្តីដែលស្ថិតនៅក្រៅឃុំទេ ទាំងមេធាវីជនត្រូវចោទ និងទាំងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

ជាគោលការណ៍ កាលណាច្បាប់មិនបានហាមឃាត់មានន័យថា ច្បាប់បានអនុញ្ញាត ឬអាចធ្វើបាន គឺធ្វើបានទៅតាមតម្រូវការ និងការចាំបាច់។ ដែលនេះទំនងថា មេធាវី អាចប្រើប្រាស់ឯកសារនោះជាកម្មវត្ថុនៃការពិភាក្សាជាមួយកូនក្តី និង/ឬប្រគល់ឯកសារនោះជាច្បាប់ថតចម្លងឱ្យកូនក្តី តាមការស្ម័គ្រចិត្ត និងចាំបាច់។ ក្នុងករណីនេះ ការបែកធ្លាយការសម្ងាត់អាចកើតឡើង តែមិនមែនដោយសារមេធាវីនោះទេ គឺដោយសារកូនក្តីរបស់មេធាវីដែលមិនមែនជាក្រុមបុគ្គលដែលត្រូវបានតម្រូវឱ្យរក្សាការសម្ងាត់នៃការស៊ើបសួរដោយក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.២. សមត្ថកិច្ចនៃការស៊ើបសួរ

សមត្ថកិច្ចនៃការស៊ើបសួរ សំដៅដល់សមត្ថកិច្ចចំពោះប្រភេទរឿងក្តី និងសមត្ថកិច្ចដែនដីរបស់ចៅក្រមស៊ើបសួរ។ សមត្ថកិច្ចរឿងក្តីចៅក្រមស៊ើបសួរ មានយុត្តាធិការស៊ើបសួរតែលើសំណុំរឿងព្រហ្មទណ្ឌដែលមានចែងដោយច្បាប់ និងបានបញ្ជូនឱ្យស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា ឬតាមនីតិវិធីបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមលក្ខខណ្ឌដែលមានចែងនៅមាត្រា ១៣៨ ដល់មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ចំពោះសមត្ថកិច្ចដែនដីវិញ ៖

- ចៅក្រមស៊ើបសួរនាទីកន្លែងបទល្មើស
- ចៅក្រមស៊ើបសួរនាទីលំនៅឋាន ឬទីសំណាក់របស់បុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស
- ចៅក្រមស៊ើបសួរនាទីកន្លែងចាប់ខ្លួនបុគ្គលដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ក្នុងករណីមានទំនាស់រវាងចៅក្រមស៊ើបសួរច្រើនរូបនៅសាលាដំបូងខុសៗគ្នា ហើយទទួលបណ្តឹងទាំងអស់គ្នាអំពីរឿងព្រហ្មទណ្ឌតែមួយដូចគ្នា ទំនាស់នេះត្រូវបញ្ជូនទៅប្រធានសភាស៊ើបសួរដើម្បីសម្រេច។ វិវាទសមត្ថកិច្ចដែនដីរវាងសភាស៊ើបសួរច្រើនត្រូវសម្រេចដោយប្រធានតុលាការកំពូល ហើយការសម្រេចនេះបិទផ្លូវតវ៉ា។[2]

ទោះយ៉ាងណា សមត្ថកិច្ចដែនដីនៃយុត្តាធិការស៊ើបសួរនេះ ត្រូវបានលើកលែងចំពោះករណីពិសេសមួយចំនួនដើម្បីជាប្រយោជន៍ដល់ការស៊ើបសួរ។ ករណីពិសេសនេះ គឺសមត្ថកិច្ចនៃការស៊ើបសួរសំណុំរឿងព្រហ្មទណ្ឌត្រូវបានផ្ទេរទៅតុលាការផ្សេងដែលមិនមានសមត្ថកិច្ចដែនដី។ សំណុំរឿងមួយចំនួន ដែលពាក់ព័ន្ធករណីពិសេសនេះរួមមាន៖

- សំណុំរឿងពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់នៅតំបន់កន្ទុយនាគ ខេត្តរតនៈគិរី ពាក់ព័ន្ធនឹងអតីតអភិបាល និងស្នងការខេត្តរតនៈគិរី និងមន្ត្រីសំខាន់ៗមួយចំនួន ត្រូវបានបញ្ជូនទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីមានសមត្ថកិច្ចស៊ើបសួរ

[2] មាត្រា ១២៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- សំណុំរឿងដែលប្តឹងដោយព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ករណីប៉ុនប៉ងមនុស្សឃាត/ហិង្សាដោយចេតនា ប្រឆាំងនឹងមន្ត្រីធ្វើការនៅសាលាខេត្តកំពង់ធំ ត្រូវបានបញ្ជូនទៅសាលាដំបូងខេត្តសៀមរាប ដើម្បីមានសមត្ថកិច្ចស៊ើបសួរ។

## ២.៣. ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ ត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ គឺតែឆ្លងកាត់នូវការស៊ើបសួររបស់ចៅក្រមស៊ើបសួរ ដើម្បីស្វែងរកនូវយុត្តិធម៌ពិតប្រាកដមួយដោយ និងអនុវត្តឱ្យបានឆាប់រហ័សបំផុតព្រោះបទល្មើសឧក្រិដ្ឋងាយបង្កឱ្យមានស្ថានភាពអាណាធិបតេយ្យ និងអសន្តិសុខ ហើយពាក់ព័ន្ធទៅនឹងអាយុជីវិតមនុស្សផងដែរ។ ចំណែកឯ បទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន ដោយយោងទៅតាមការសម្រេចពីព្រះរាជអាជ្ញា និងស្ថានភាពនៃបទល្មើស ក្នុងករណីដែលព្រះរាជអាជ្ញាពិនិត្យឃើញថាមានភស្តុតាង និងសាក្សីគ្រប់គ្រាន់ ដោយធ្វើដីកាបញ្ជូនទៅជំនុំជម្រះតែម្តង។[3] ការបើកការស៊ើបសួរមានគោលបំណងក្នុងការស្វែងរកនូវធាតុចាំបាច់សម្រាប់ធានាដល់ការចោទប្រកាន់របស់ព្រះរាជអាជ្ញា តាមរយៈបណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញនូវពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសតាមច្បាប់កំណត់។ បណ្តឹងអាជ្ញា អនុវត្តទៅលើបុគ្គលគ្រប់រូបទាំងរូបវន្តបុគ្គល ទាំងនីតិបុគ្គល ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ បណ្តឹងអាជ្ញា ត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅរបស់សង្គម ហើយតំណាងអយ្យការ ធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ។

លក្ខខណ្ឌដែលនាំឱ្យមានការបើកការស៊ើបសួរ មានលក្ខខណ្ឌចំនួនពីរគឺ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលយើងហៅសាមញ្ញថា ជាដីកាផ្តើមចោទប្រកាន់របស់ព្រះរាជអាជ្ញា និងការបើកការស៊ើបសួរតាមរយៈជនរងគ្រោះ។ ជាទូទៅចំពោះរឿងក្តីព្រហ្មទណ្ឌដើម្បីឱ្យតំណាងអយ្យការ ចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ត្រូវមានផ្លូវជម្រើសនៃបណ្តឹងពីរគឺ បណ្តឹងសាមញ្ញ និងបណ្តឹងតាមផ្លូវអន្តរាគមន៍។

### ២.៣.១. បណ្តឹងជាលក្ខខណ្ឌនាំឱ្យមានការបើកការស៊ើបសួរ

#### ក. បណ្តឹងសាមញ្ញ

ក្នុងករណីដែលភាគីជាជនរងគ្រោះ បានទទួលរងនូវព្យសនកម្មពីអំពើល្មើសណាមួយ ឬអាជ្ញាធរសាធារណៈនៅក្នុងការបំពេញមុខងាររបស់ខ្លួន ឬតតិយជន បានដឹងអំពីបទល្មើស អាចដាក់ពាក្យប្តឹងទាមទារ ឬប្តឹងបរិហារ ទៅអង្គភាពនគរបាលយុត្តិធម៌ ឬដាក់ពាក្យដោយផ្ទាល់ទៅព្រះរាជអាជ្ញា។

[3] មាត្រា ៤៤, មាត្រា ១២២ និង មាត្រា ១២៤ ក្រមនីតិវិធីព្រហ្មទណ្ឌ

ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្ដឹងដែលខ្លួនបានទទួលពីជនរងគ្រោះ ឬតតិយជន ដែលបានប្ដឹងបរិហារ។ បន្ទាប់ពីបានថ្លឹងថ្លែងលើពាក្យប្ដឹងរួច ព្រះរាជអាជ្ញាអាចសម្រេចតម្កល់ទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់តាមឆន្ទានុសិទ្ធិរបស់ខ្លួន។[4]

កាលណា បណ្ដឹងណាមួយត្រូវតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្ដឹងអំពីសេចក្ដីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ ខែ គិតពីថ្ងៃចុះពាក្យប្ដឹងក្នុងបញ្ជី។

ប្រសិនបើ អ្នកប្ដឹងមិនសុខចិត្តនឹងសេចក្ដីសម្រេចតម្កល់រឿងទុកឥតចាត់ការ គឺសាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ហើយការតវ៉ានេះត្រូវធ្វើនៅក្នុងរយៈពេល ២ ខែ គិតពីថ្ងៃទទួលដំណឹងអំពីសេចក្ដីសម្រេចតម្កល់ទុកឥតចាត់ការ។[5] ការតវ៉ានេះត្រូវធ្វើតាមបណ្ដឹងសាមញ្ញ នៅអង្គការអយ្យការដែលពាក់ព័ន្ធ។ បន្ទាប់មក សំណុំរឿងត្រូវបញ្ជូនភ្លាម ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការអមសាលាដំបូង។ ប្រសិនយល់ឃើញថា មានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចេញអធិបញ្ញាដល់ព្រះរាជអាជ្ញាអមសាលាដំបូង ឱ្យធ្វើការចោទប្រកាន់។ អគ្គព្រះរាជអាជ្ញាធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ ក្នុងករណីផ្ទុយពីនេះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ តម្កល់សេចក្ដីសម្រេច របស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្ដីសម្រេចនេះ ដល់អ្នកប្ដឹងតវ៉ា។

### ខ. បណ្ដឹងតាមផ្លូវអន្តរាគមន៍

ការធ្វើឱ្យបណ្ដឹងអាជ្ញាមានចលនាបានដោយជនរងគ្រោះ យោងតាមមាត្រា ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានបញ្ញត្តិថា ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ។ ពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មានអានុភាពប្ដឹងដល់ចៅក្រមស៊ើបសួរ។ កាលណាការស៊ើបសួរត្រូវបានបើក បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនថា ជាជនរងគ្រោះអាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា។

ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ធ្វើឡើងដោយគ្មានតម្រូវតាមទម្រង់ណាមួយឡើយ។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានធ្វើឡើងតាមលិខិតនឹងត្រូវដាក់បញ្ចូលក្នុងសំណុំរឿងការតាំងខ្លួនត្រូវបានធ្វើឡើងផ្ទាល់មាត់ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុ។ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹង អំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះ ដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ចៅក្រមស៊ើបសួរ ធ្វើការកត់សម្គាល់នូវការដាក់ពាក្យបណ្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមដីកា ហើយចៅក្រមស៊ើបសួរ បញ្ជូនបណ្ដឹងនេះទៅ

[4] មាត្រា ៤០ និងមាត្រា ៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[5] មាត្រា ៤១ កថាខណ្ឌទី៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ព្រះរាជអាជ្ញា។ ក្រោយពីបានឃើញពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ព្រះរាជអាជ្ញា ត្រូវប្តឹងទៅចៅក្រមស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

យើងនឹងធ្វើការបកស្រាយលំអិតអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំណុចជំពូកទី២ ការបើកការស៊ើបសួរ និងការប្តឹងទៅចៅក្រមស៊ើបសួរ កថាខណ្ឌទី២ បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ២.១. ការប្តឹងដោយដើមបណ្តឹងរដ្ឋប្បវេណី។

### ២.៣.២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការស៊ើបសួរត្រូវបានបើកដោយ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់ព្រះរាជអាជ្ញាដោយអនុលោមតាមមាត្រា ៤៤ (ការបើកការស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ការស៊ើបសួរ អាចបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬប្រឆាំងនឹងអញ្ញាតជន។

ចៅក្រមស៊ើបសួរ មិនអាចបំពេញកិច្ចស៊ើបសួរណាមួយបានដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ។

#### ក. លក្ខណៈនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន និង
- ត្រូវចុះកាលបរិច្ឆេទ ហត្ថលេខា និង បោះត្រា របស់តំណាងអយ្យការ។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។[6]

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាលិខិតបើកឱ្យមានបណ្តឹងអាជ្ញា ដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរ ដោយសុំឱ្យស៊ើបសួរលើរឿងរ៉ាវមួយជាកំណត់ ដែលអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ។ ការចុះកាលបរិច្ឆេទមានអត្ថប្រយោជន៍ ដើម្បីធ្វើការផ្ទៀងផ្ទាត់ថាបណ្តឹងអាជ្ញាមិនទាន់ផុតអាជ្ញាយុកាល ហើយចៅក្រមស៊ើបសួរ មិនបានស៊ើបសួរមុនពេលទទួលបណ្តឹងទេ។ រីឯ ការចុះហត្ថលេខារបស់ព្រះរាជអាជ្ញា ដែលបានចេញដីកាសម្រេចឱ្យបើកការស៊ើបសួរនេះ ដើម្បីបញ្ជាក់ពីឆន្ទៈរបស់អង្គការអយ្យការក្នុងការចោទប្រកាន់។

#### ខ. ប្រភេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

---

[6] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប្រភេទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានដូចជា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំពោះអង្គហេតុជាក់ស្តែង និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំពោះអង្គហេតុមិនជាក់ស្តែង។

ចំពោះដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំពោះអង្គហេតុជាក់ស្តែង គឺចៅក្រមស៊ើបសួរ ដែលទទួលសំណុំរឿងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចំពោះអង្គហេតុជាក់ស្តែង ចៅក្រមទទួលសំណុំរឿង និងជនត្រូវចោទ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ទទួលនូវសំណុំរឿង និងទទួលនូវជនត្រូវចោទ ដែលឃុំគ្រងដោយកងកម្លាំងមានសមត្ថកិច្ច នឹងត្រូវនាំមកចំពោះមុខ ដែលតំណាងអយ្យការចោទប្រកាន់តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ចំណែកឯ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំពោះអង្គហេតុមិនជាក់ស្តែង គឺចៅក្រមស៊ើបសួរ ដែលទទួលសំណុំរឿងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរចំពោះអង្គហេតុមិនជាក់ស្តែងចៅក្រមទទួលតែសំណុំរឿងប៉ុណ្ណោះ។

## កថាខណ្ឌទី៣ វិធានការនិរន្តរាយ

វិធានការនិរន្តរាយ គឺសំដៅលើដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាចាប់ខ្លួន ដីកាបង្គាប់ឱ្យឃុំខ្លួន និងដីកាដាក់ឱ្យជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលចេញដោយចៅក្រមស៊ើបសួរ។ ដើម្បីធានាដល់ប្រសិទ្ធិភាពនៃការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវប្រើអំណាចបង្ខំដោយប្រើវិធានការនិរន្តរាយ ទៅលើជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព ដែលមិនព្រមចូលខ្លួនតាមការកោះហៅ ក្នុងដំណាក់កាលស៊ើបសួរ។ វិធានការនិរន្តរាយនេះអាចអនុវត្ត ទៅលើនីតិជន (អាយុចាប់ពី១៨ឆ្នាំឡើង) និងអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ដែលមានតម្រុយប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។[7]

យើងខ្ញុំនឹងធ្វើការបកស្រាយទៅលើចំណុច (**៣.១.**). ដីកាបង្គាប់ឱ្យចូលខ្លួន (**៣.២.**). ដីកាបង្គាប់ឱ្យនាំខ្លួន (**៣.៣.**).ដីកាបង្គាប់ឱ្យចាប់ខ្លួន (**៣.៤.**).ដីកាបង្គាប់ឱ្យឃុំខ្លួន និង(**៣.៥.**). ការអនុវត្តដីកា។

### ៣.១. ដីកាបង្គាប់ឱ្យចូលខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាការបញ្ជាដល់បុគ្គលណាម្នាក់ ឱ្យចូលទៅបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ។ ដីកានេះ អាចចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពប៉ុណ្ណោះ។ ដីកានេះត្រូវជូនដំណឹងដល់ជនពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា។ បុគ្គលដែលពាក់ព័ន្ធទទួលចុងដីកា ត្រូវចុះហត្ថលេខាលើដើមដីកា ដែលនឹងត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ ហើយមន្ត្រីនគរបាលយុត្តិធម៌ ឬអាជ្ញាសាលា ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកម្មរបស់ខ្លួន។[8]

ដីកាបង្គាប់ឱ្យចូលខ្លួន មាននិទ្ទេសដូចតទៅ ៖

- អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

[7] មាត្រា ១៨៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[8] មាត្រា ១៨៦, ១៨៧ និង១៨៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងដែលត្រូវចូលបង្ហាញខ្លួននៅមុខចៅក្រមស៊ើបសួរ
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

តាមរយៈដីកានេះ សាម៉ីខ្លួនបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដោយសេរី មានន័យថា ការបង្ហាញខ្លួនតាមរយៈដីកានេះ ពុំមានតម្លៃបង្ខំ ដោយកងកម្លាំងសាធារណៈនោះទេ។ ដីកានេះ គឺជាការបញ្ជាឱ្យសាម៉ីខ្លួនចូលបង្ហាញខ្លួនតាមផ្លូវធម្មតា ដែលជាទូទៅដីកានេះត្រូវបានប្រើប្រាស់នៅពេល ដែលសាម៉ីជននោះមិនបានរត់គេចខ្លួន ហើយពុំឆ្លើយតបទៅនឹងការកោះហៅតាមផ្លូវរដ្ឋបាល។

### ៣.២. ដីកាបង្គាប់ឱ្យនាំខ្លួន

ដីកានេះ គឺជាបញ្ជាដែលមានតម្លៃបង្ខំ ដែលបង្គាប់ដល់កងកម្លាំងសាធារណៈឱ្យចាប់ខ្លួន និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យនាំខ្លួនអាចចេញ ទៅបានតែលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ដែលមានតម្រុយពីពិរុទ្ធភាពតែប៉ុណ្ណោះ។ ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលមានកាតព្វកិច្ចនាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅចំពោះមុខចៅក្រមស៊ើបសួរ ក្រោយពេលចាប់ខ្លួនបាន។ ប៉ុន្តែ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនអាចសួរចម្លើយជន នោះភ្លាមៗ ឬដោយមូលហេតុនៃកាលៈទេសៈបុគ្គលដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរបានភ្លាមៗទេ ដីកានេះ បានអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌នាំខ្លួនបុគ្គលដែលពាក់ព័ន្ធទៅរក្សាទុកនៅ អង្គភាពក្នុងមណ្ឌលឃុំខ្លួន ឬពន្ធនាគារបានដែលមានថិរវេលាមិនអាចលើសពី ១ ថ្ងៃបានឡើយ ពោលគឺត្រូវតែនាំខ្លួនបុគ្គលដែលពាក់ព័ន្ធនេះទៅចំពោះមុខចៅក្រមស៊ើបសួរ យ៉ាងយូរបំផុតនៅថ្ងៃបន្ទាប់។ ផ្ទុយពីនេះ ប្រសិនបើជាការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលដែលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ។ ប្រការមួយទៀតដែលត្រូវជៀសវាងដាច់ខាត ដើម្បីកុំឱ្យមានការរំលោភលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួន មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ បានទេ។[9]

កាលណាបុគ្គលណាម្នាក់ ដែលត្រូវបានចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានឃុំខ្លួន នោះថិរវេលានៃការឃុំខ្លួននេះ ត្រូវរាប់បញ្ចូលទៅក្នុងថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើមាន។[10]

### ៣.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួន មានតួនាទី ៣ គឺ ស្វែងរក ចាប់ខ្លួន និងឃុំខ្លួន។ ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាការបញ្ជាដល់កងកម្លាំងសាធារណៈឱ្យធ្វើការស្រាវជ្រាវចាប់ខ្លួន និងនាំខ្លួនបុគ្គលនោះ ទៅដាក់ពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។

[9] មាត្រា ១៩០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[10] មាត្រា ១៩៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

លក្ខខណ្ឌនៃការចេញដីកា លុះត្រាតែបទល្មើសដែលត្រូវបានចោទប្រកាន់ជាបទមជ្ឈិម ឬជាបទឧក្រិដ្ឋ ដែលនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ហើយបុគ្គលដែលពាក់ព័ន្ធបានគេចខ្លួន មិនដឹងជាស្ថិតនៅទីកន្លែងណា ឬនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួននេះ ចៅក្រមស៊ើបសួរត្រូវតែទទួលយោបល់ព្រះរាជអាជ្ញាដោយមានចែងមូលហេតុ ហើយព្រះរាជអាជ្ញា ធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួននេះ។ ការអនុវត្តដីកានេះត្រូវប្រគល់ ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ដែលមានកាតព្វកិច្ចស្វែងរក, ចាប់ខ្លួន និងនាំបុគ្គលដែលពាក់ព័ន្ធទៅពន្ធនាគារ ឬមណ្ឌលឃុំ។ បុគ្គលដែលពាក់ពន្ធត្រូវតែបានគេនាំទៅបង្ហាញដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួសចៅក្រមស៊ើបសួរនៅថ្ងៃបន្ទាប់ពីការចាប់។

ដូចគ្នានឹងការប្រតិបត្តិដីកាបង្គាប់ឱ្យនាំខ្លួនដែរ ប្រការដែលត្រូវជៀសវាងដាច់ខាត ដើម្បីកុំឱ្យមានការរំលោភលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិធម៌ដែលអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួន មិនអាចចូលទៅលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ បានទេ។ ក្នុងករណីដែលត្រូវចាប់ខ្លួនដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវបានឃុំខ្លួននោះថិរវេលានៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលក្នុងថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននោះដែរ។

**គួរកត់សម្គាល់ថា៖** ចំពោះដីកាទាំងបីខាងលើនេះ ចៅក្រមស៊ើបសួរ អាចចេញបានដោយថ្លឹងថ្លែងទៅតាមស្ថានភាព និងកាលៈទេសៈនៃសំណុំរឿងនីតិវិធី ដោយមិនចាំបាច់មានលំដាប់លំដោយនោះទេ។

### ៣.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឱ្យឃុំខ្លួនជនត្រូវចោទរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។[11]

ចៅក្រមស៊ើបសួរ អាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន ដោយមានសេចក្តីសម្រេច ឱ្យឃុំខ្លួនបណ្តោះអាសន្នជាមុនសិន ហើយបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់បាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ។[12] ត្រង់ចំណុចចុងក្រោយនេះ បញ្ជាក់យ៉ាងច្បាស់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែរ តាមន័យនេះ ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឱ្យឃុំខ្លួនបុគ្គលណាម្នាក់ ដោយមិនមានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននោះឡើយ។[13]

### ៣.៥. ការអនុវត្តដីកា

ដីកាត្រូវបានអនុវត្តនៅលើវិសាលភាពដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដីកានេះអនុវត្តរហូតដល់មានលិខិតជាក់លាក់ពីអាជ្ញាធរតុលាការ ដែលដកយកមកវិញ ជំនួសមកវិញ ឬលុបចោលនូវដីកាទាំងនោះ។ ដូចនេះវិនិច្ឆ័យដែលសម្រេចពីជោគវាសនារបស់បុគ្គលដែលពាក់ព័ន្ធ ក្នុងការសម្រេចទុកដីកាទាំងនេះជាមោឃៈ ឬចេញដីកាផ្សេងទៀត។

[11] មាត្រា ២១៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[12] មាត្រា ២២០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[13] មាត្រា ២២២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គ្រប់ដីកាទាំងអស់មានលក្ខណៈរួមមួយ គឺបង្ខំឱ្យមានការសួរចម្លើយបុគ្គលដែលពាក់ព័ន្ធ ដោយចៅក្រមស៊ើបសួរដែលចេញដីកា ក្នុងពេលណាមួយនៃនីតិវិធីក៏បាន។ ចំពោះដីកាបង្គាប់ឱ្យនាំខ្លួនធ្វើឡើងក្នុងលក្ខខណ្ឌតែមួយ នឹងដីកាបង្គាប់ឱ្យចូលខ្លួន មានន័យថាការសួរចម្លើយដោយចៅក្រមស៊ើបសួរ ត្រូវធ្វើភ្លាម លើកលែងតែមានឧបសគ្គ។ ការអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន ចាប់ផ្ដើមពីការជូនដំណឹងទៅបុគ្គលដែលចៅក្រមស៊ើបសួរចង់ស្តាប់ចម្លើយនៅក្នុងការិយាល័យ ឬមន្ទីរស៊ើបសួរបស់ចៅក្រមស៊ើបសួរ នៅថ្ងៃនិងម៉ោង ដែលបានកំណត់ក្នុងដីកានោះ។ ចាប់ពីពេលដែលចេញដីកា បុគ្គលដែលពាក់ព័ន្ធបានដឹងថាខ្លួនឯង ត្រូវបានសង្ស័យ ហើយប្រសិនបើជាមិនចូលបង្ហាញខ្លួននៅការិយាល័យរបស់ចៅក្រមស៊ើបសួរទេ ដំណាក់កាលបន្ទាប់ច្បាស់ជាដីកាបង្គាប់ឱ្យនាំខ្លួន ឬដីកាបង្គាប់ឱ្យចាប់ខ្លួន។

## ផ្នែកទី២ ការបើកការស៊ើបសួរ និងការប្ដឹងទៅចៅក្រមស៊ើបសួរ

### កថាខណ្ឌទី១ ការប្ដឹងដោយព្រះរាជអាជ្ញា

#### ១.១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

ការស៊ើបសួរ ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងករណី ដែលពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាទេ គឺចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរដោយឯកឯងបានឡើយ។[14] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ អាចធ្វើឡើងប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានការចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។ ដូចនេះដីកាសន្និដ្ឋាននេះ គឺជាលិខិតដែលបើកឱ្យមានបណ្ដឹងអាជ្ញាដែលព្រះរាជអាជ្ញា ប្ដឹងទៅចៅក្រមស៊ើបសួរ ដោយសុំឱ្យធ្វើការស៊ើបសួរលើអង្គហេតុមួយ ឬច្រើនជាកំណត់ដែលអាចត្រូវផ្ដន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

- សេចក្ដីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងហត្ថលេខារបស់ព្រះរាជអាជ្ញា។ ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នោះទេ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ។[15]

ក្នុងពេលបំពេញកិច្ចស៊ើបសួរ ចៅក្រមស៊ើបសួរ មានសិទ្ធិអំណាចត្រូវតែដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលមានចង្អុលប្រាប់ឈ្មោះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ទោះបីជា បុគ្គលនោះគ្មានការចង្អុល

[14] មាត្រា ១២៤ កថាខណ្ឌទី៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[15] មាត្រា ៤៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងថា បានចូលរួមប្រព្រឹត្តបទល្មើស។[16]

### ១.២. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម

ចៅក្រមស៊ើបសួរ ទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ហើយចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអំពីអង្គហេតុនោះប៉ុណ្ណោះ។

ប្រសិនបើមានលេចអង្គហេតុថ្មី ដែលជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា ហើយព្រះរាជអាជ្ញាអាចប្តឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ប្រសិនបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរក៏គ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។

ប៉ុន្តែចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង។[17]

## កថាខណ្ឌទី២ បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

### ២.១. ការប្តឹងដោយដើមបណ្តឹងរដ្ឋប្បវេណី

ចៅក្រមស៊ើបសួរ ក៏អាចទទួលបណ្តឹងតាមរយៈបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងដោយជនរងគ្រោះខ្លួនឯងផ្ទាល់ ឬដោយមេធាវី ក្នុងនាមរបស់ជនរងគ្រោះ។[18] បន្ទាប់ពីធ្វើការកត់សម្គាល់តាមដីកានូវការដាក់ពាក្យបណ្តឹងរួចមក ចៅក្រមស៊ើបសួរបញ្ជូនពាក្យបណ្តឹង ទៅព្រះរាជអាជ្ញាដើម្បីឱ្យព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋាន។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរអាចធ្វើឡើងប្រឆាំងជនស្គាល់ឈ្មោះ ឬជនមិនស្គាល់ឈ្មោះ។ ក្នុងគ្រប់ករណីទាំងអស់ ត្រូវមានលិខិតរបស់អយ្យការ ដូចនេះបណ្តឹងអាជ្ញានឹងត្រូវបានបើកដោយត្រឹមត្រូវ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់ព្រះរាជអាជ្ញា ទោះបីជាការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបដិសេធក៏ដោយ។

ប៉ុន្តែព្រះរាជអាជ្ញា អាចសុំកុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ដោយសារមានការរលត់បណ្តឹងអាជ្ញា ឬដោយសារអវត្តមាននៃបទល្មើសព្រហ្មទណ្ឌ ព្រោះអំពើដែលបរិហារ ដោយជនរងគ្រោះមិនអាចត្រូវបានស្តីបន្ទោសបាន។ ប្រសិនបើចៅក្រមស៊ើបសួរសម្រេចមិនបន្តការស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវចេញដីកាដោយមានសំអាងហេតុដែលត្រូវជូនដំណឹងដល់ជនរងគ្រោះ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចធ្វើបណ្តឹងឧទ្ធរណ៍ពីដីកាសម្រេចរបស់

---

[16] មាត្រា ១២៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[17] មាត្រា ១២៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[18] មាត្រា ១៣៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរ ដែលអាចជាដីកាមិនព្រមស៊ើបសួរ ឬដីកាប្រកាសមិនទទួលបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវជូនដំណឹងទៅដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងខ្លីបំផុត។

ដើម្បីការពារកុំឱ្យមានពាក្យបណ្ដឹងដោយបំពាននៅក្នុងករណីនេះ បុគ្គលដែលប្ដឹងមានកាតព្វកិច្ចត្រូវបង់ប្រាក់តម្កល់ទុក។ ចំពោះការបង់ប្រាក់តម្កល់ទុក ដោយផ្អែកទៅលើធនធាននៃដើមបណ្ដឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចមើលឃើញជាមុន ចៅក្រមស៊ើបសួរកំណត់តាមដីកាសម្រេចនូវចំនួនទឹកប្រាក់ ដែលដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផង។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី ពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ ចៅក្រមសួរអាចលើកលែងមិនឱ្យបង់ប្រាក់នេះបាន។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ក្នុងករណីដែលមានការបង់ប្រាក់តម្កល់ទុក ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបង្កាន់ដៃ ដែលមានចុះហត្ថលេខា ដោយប្រធានតុលាការ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី។

ប្រសិនបើប្រាក់តម្កល់ទុក មិនត្រូវបានបង់នៅក្នុងរយៈពេល ដែលកំណត់ដោយចៅក្រមស៊ើបសួរទេ ពាក្យប្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវប្រកាសថា មិនអាចទទួលបានដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរនេះ សម្រេចតាមដីកាដែលត្រូវជូនដំណឹង ជាបន្ទាន់ដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រាក់តម្កល់ទុកត្រូវបង្វិលទៅសាមីខ្លួននៅពេលបញ្ចប់នីតិវិធី។

ប្រាក់តម្កល់ទុក ត្រូវតម្កល់ទុកនៅក្នុងគណនីពិសេស ដែលបើកនៅក្នុងធនាគារ ឬ រក្សាទុកនៅក្នុងទីកន្លែងដែលមានការធានាសន្តិសុខយ៉ាងរឹងមាំ ហើយទីកន្លែងនេះ ត្រូវបានជ្រើសរើសតាមការព្រមព្រៀងគ្នារបស់ប្រធានតុលាការ និងព្រះរាជអាជ្ញា។[19]

## ២.២. ក្រោយពីទទួលបានបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ប្រសិនបើការស៊ើបសួរដែលបានបើកបន្ទាប់ពីមានពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ ហើយប្រសិនបើ ចៅក្រមស៊ើបសួរយល់ឃើញថា នីតិវិធីធ្វើឡើងដោយរំលោភ ឬដោយអូសបន្លាយពេលវេលា នោះចៅក្រមស៊ើបសួរអាចសម្រេចតាមដីកាសម្រេចឱ្យដើមបណ្ដឹងបង់ប្រាក់ពិន័យរដ្ឋប្បវេណី ហើយចំនួនប្រាក់ពិន័យមិនអាចលើសចំនួនទឹកប្រាក់តម្កល់ទុកឡើយ។ ដីកាសម្រេចឱ្យបង់ប្រាក់ពិន័យនេះ ត្រូវឱ្យដំណឹងដល់សាមីខ្លួនជាបន្ទាន់។[20]

កាលណាការស៊ើបសួរដែលបើកបន្ទាប់ពីមានពាក្យប្ដឹង ដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបិទតាមដីកាលើកលែងចោទប្រកាន់ចូលជាស្ថាពរ បុគ្គលដែលមានឈ្មោះនៅក្នុងពាក្យប្ដឹង អាចប្ដឹងសុំការជួសជុលសំណងពីអ្នកដែលប្ដឹងពីខ្លួន ប្រសិនបើនីតិវិធីធ្វើឡើង ដោយរំលោភ ឬដោយអូសបន្លាយពេលវេលា។ ពាក្យប្ដឹងសុំ

[19] មាត្រា ១៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[20] មាត្រា ១៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការជួសជុលនេះ ត្រូវដាក់ជូនដល់តុលាការជាន់ដំបូងដែលរឿងត្រូវបានស៊ើបសួរ។ តុលាការអាចសុំឱ្យគេបញ្ជូនសំណុំរឿងមកពិនិត្យ។[21]

ក្រោយពីទទួលពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរអាច ៖

- សម្រេចមិនស៊ើបសួរតាមការចេញដីកាសម្រេច ដោយមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ទៅដើមបណ្តឹងរដ្ឋប្បវេណី ឬ
- បញ្ជូនបណ្តឹងខាងលើទៅព្រះរាជអាជ្ញា។

ក្រោយពីទទួលបណ្តឹងពីចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាអាចសម្រេចថា ៖

- សុំទៅចៅក្រមស៊ើបសួរកុំឱ្យស៊ើបសួរ ប្រសិនបើ បណ្តឹងអាជ្ញាត្រូវបានផុតរលត់ ឬប្រសិនបើ អំពើដែលត្រូវប្តឹងនេះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ឬ
- ចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយប្តឹងឱ្យចៅក្រម បើកការស៊ើបសួរទៅតាមនីតិវិធីច្បាប់។

ក្រោយទទួលបានការឆ្លើយតបពីព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរអាច៖

- នៅតែបើកការស៊ើបសួរ បើទោះបីជា ព្រះរាជអាជ្ញាមិនចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងស្នើសុំមិនឱ្យបើកការស៊ើបសួរយ៉ាងណាក្តី
- បើកការស៊ើបសួរ តាមការចង្អុលបង្ហាញដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។

បច្ចុប្បន្ន នីតិវិធីលើករណីបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ កម្រនឹងឃើញកើតមានណាស់ ហើយម្យ៉ាងនីតិវិធីនេះ អាចអនុវត្តបានងាយស្រួលចំពោះតុលាការ ដែលមានការចាត់តាំងឱ្យមានចៅក្រមស៊ើបសួរជាស្រេច សម្រាប់បំពេញតែកិច្ចជំនាញផ្នែកស៊ើបសួរ តាមគោលបំណងនៃច្បាប់ស្តីពី ការរៀបចំអង្គការតុលាការរបស់កម្ពុជា។ ការលើកឡើងនេះ មិនមានន័យថា តុលាការបច្ចុប្បន្ន មិនអាចដំណើរការនីតិវិធីខាងលើទេ ព្រោះថាបើទោះបីជា សាលាដំបូងរាជធានី-ខេត្ត មិនទាន់ចាត់តាំងចៅក្រមទទួលបន្ទុកតែការស៊ើបសួរយ៉ាងណាក្តី តែប្រធានសាលាដំបូងនៅតែអាចចាត់តាំងចៅក្រមក្នុងការចាត់ការបណ្តឹងខាងលើនេះបានទៅតាមច្បាប់។

[21] មាត្រា ១៤២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី២

# ការឃុំខ្លួនបណ្តោះអាសន្ន

# ជំពូកទី២

# ការឃុំខ្លួនបណ្តោះអាសន្ន

## ផ្នែកទី១ គោលបំណងនៃការឃុំខ្លួនបណ្តោះអាសន្ន

តាមស្ថានភាពជាក់ស្តែងនៃសង្គមបច្ចុប្បន្ន នៅពេលកើតមានបទល្មើសណាមួយ ដែលមានចរិតលក្ខណៈធ្ងន់ធ្ងរ ជនដែលបានប្រព្រឹត្តបទល្មើសអាចនឹងត្រូវបានគេឃាត់ខ្លួនភ្លាមៗ ឬអាចសម្រេចឃុំខ្លួនជាដើម ដើម្បីធានាបាននូវសណ្តាប់ធ្នាប់ ឬកើតមានផលប៉ះពាល់កាន់តែធ្ងន់ធ្ងរជាងមុនពីអំពើល្មើសនោះ។

ប៉ុន្តែមិនមែនគ្រប់ពេលដែលមានបទល្មើសកើតឡើង ការសម្រេចឃុំត្រូវតែធ្វើឡើងនោះទេ ពោលគេត្រូវសិក្សាទៅលើស្ថានភាពនៃបទល្មើស ក៏ដូចជាស្ថានភាពជន ដែលបានប្រព្រឹត្តបទល្មើសជាមុនសិន ដើម្បីជៀសវាងថាការសម្រេចឃុំខ្លួននោះ នឹងអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពបុគ្គលរបស់គេ។

ដើម្បីស្វែងយល់ពីនីតិវិធីនេះឱ្យបានច្បាស់ យើងនឹងធ្វើការបកស្រាយក្នុង **កថាខណ្ឌទី១ ទស្សនៈទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន** **កថាខណ្ឌទី២ ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន** និង **កថាខណ្ឌទី៣ នីតិវិធីនៃសម្រេចការឃុំខ្លួនបណ្តោះអាសន្ន** នៅខាងក្រោមនេះ។

### កថាខណ្ឌទី១ ទស្សនៈទូទៅនៃការឃុំខ្លួនបណ្តោះអាសន្ន

#### ១.១. គោលការណ៍ក្នុងដំណាក់កាលស៊ើបសួរ

គោលការណ៍នៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងក្នុងមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមស្មារតីនៃមាត្រា ២០៣ នេះ ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ហើយក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្នក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ទន្ទឹមនេះ ក្រមនីតិវិធីព្រហ្មទណ្ឌក៏ចែងផងដែរ អំពីការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជំនួសឱ្យវិធានការ នៃការឃុំខ្លួនបណ្តោះអាសន្ន តាមរយៈការដាក់ឱ្យជនត្រូវចោទជាប់នូវកាតព្វកិច្ចមួយចំនួនដូចមានចែងក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

កន្លងមក ក្រសួងយុត្តិធម៌បានពិនិត្យឃើញថា វិធានការនៃការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ពុំសូវត្រូវបានប្រើឱ្យបានទូលំទូលាយស្របតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌនៅឡើយទេ ហើយជាទូទៅចៅក្រមស៊ើបសួរ បានប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការសម្រេចជ្រើសយកការឃុំខ្លួនបណ្តោះអាសន្ន ជាវិធានការនិរន្តរាយ ដើម្បីធានាដល់ដំណើរការនៃការស៊ើបសួរ ដែលជាកត្តារួមចំណែកនាំឱ្យមានការកើនឡើងនៃជនជាប់ឃុំនៅតាមពន្ធនាគារ។

ដោយឡែកសន្និសិទ ស្តីពីការណែនាំពីការអនុវត្តដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្នលេខ៖ ១២០ កយ.រប/១៤ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ របស់ចុះក្រសួងយុត្តិធម៌ បានសង្កត់ធ្ងន់ពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្តោះអាសន្នថា

**« ចៅក្រមស៊ើបសួរ ត្រូវព្យាយាមសួរព័ត៌មានឱ្យបានច្រើនពាក់ព័ន្ធនឹងស្ថានភាពរស់នៅរបស់ជនត្រូវចោទ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចឃុំខ្លួន ឬមិនឃុំខ្លួន ដូចជាជនត្រូវចោទមានផ្ទៃពោះ ជាស្ត្រីកំពុងបំបៅដោះកូន ជាស្ត្រីមានកូនតូចៗនៅជាមួយដោយគ្មានអ្នកណាផ្សេងជួយមើលថែកូនតូចៗទាំងនោះ ឬជនត្រូវចោទជាមនុស្សចាស់ជរា ឬក៏កំពុងមានជំងឺធ្ងន់ធ្ងរទាមទារឱ្យមានការពិនិត្យជាប្រចាំពីគ្រូពេទ្យ។ល។ ក្នុងស្ថានភាពបែបនេះ បើអាចជៀសបាន មិនគួរគប្បីឃុំខ្លួនជាបណ្ដោះអាសន្នឡើយ»។** ដើម្បីចូលរួមចំណែក ក្នុងការកាត់បន្ថយភាពចង្អៀតណែននៅតាមពន្ធនាគារ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំចំពោះការអនុវត្តវិធានការនិរន្តរាយនៅក្នុងដំណាក់កាលស៊ើបសួរដូចតទៅ៖

- ចៅក្រមស៊ើបសួរ គប្បីយកចិត្តទុកដាក់ក្នុងការពន្លឿនការអនុវត្តនីតិវិធីស៊ើបសួររបស់ខ្លួនឱ្យបានឆាប់រហ័សប្រកបដោយស្មារតីទទួលខុសត្រូវចំពោះមុខច្បាប់ និងស្របតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- ចៅក្រមស៊ើបសួរ គប្បីយកចិត្តទុកដាក់ប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុវត្តឱ្យបានត្រឹមត្រូវ ស្របតាមមាត្រា ២០៣ និងមាត្រាពាក់ព័ន្ធបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន ជាពិសេសស្មារតីនៃការគោរពគោលការណ៍សេរីភាពជាចម្បង និងគោលការណ៍សន្មតទុកជាមុនថាគ្មានទោស។ ការឃុំខ្លួនបណ្ដោះអាសន្ន គប្បីត្រូវបានប្រើសម្រាប់តែចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលមានភាពស្មុគស្មាញ និងធ្ងន់ធ្ងរ ហើយក្នុងលក្ខខណ្ឌដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ជាពិសេស ក្នុងករណីដែលការឃុំខ្លួនបណ្ដោះអាសន្ននោះ គឺជាមធ្យោបាយតែមួយគត់ និងចាំបាច់ដើម្បីធានាដល់ដំណើរការស៊ើបសួរតែប៉ុណ្ណោះ។
- លើកទឹកចិត្តឱ្យចៅក្រមស៊ើបសួរប្រើឱ្យអស់លទ្ធភាព និងឱ្យបានទូលំទូលាយ ដោយផ្អែកតាមអង្គហេតុជាក់ស្ដែងនៃសំណុំរឿងនីមួយៗ ក្នុងការសម្រេចជ្រើសរើសយកការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជាវិធានការនិរន្តរាយ ជំនួសឱ្យវិធានការនៃការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីធានាដល់ដំណើរការនៃការស៊ើបសួរ ស្របតាមបញ្ញត្តិចាប់ពីមាត្រា ២២៣ ដល់មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជាពិសេសចំពោះបទមជ្ឈិមដែលមិនមានភាពស្មុគស្មាញ និងមិនធ្ងន់ធ្ងរ។

### ១.២. យន្តការយុត្តិធម៌ព្រហ្មទណ្ឌបែបទំនើប

ទោះបីជាពេលខ្លះការឃុំខ្លួនជាបណ្ដោះអាសន្ន គឺជាភាពចាំបាច់ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រងយុត្តិធម៌ និងការពារជនរងគ្រោះ និងសាក្សីយ៉ាងណាក្ដី ក៏ការឃុំខ្លួនបណ្ដោះអាសន្ននេះ មិនអាចក្លាយជាជម្រើសតែមួយគត់នោះដែរ ព្រោះការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្នហួសប្រមាណ ឬមិនត្រឹមត្រូវអាចធ្វើឱ្យមានការរឹតត្បិតលើសិទ្ធិសេរីភាព។ ចំពោះលើកឡើងនូវការរិះគន់ ចំពោះមន្ត្រីនគរបាលដែលបានចាប់ជនដែលប្រព្រឹត្តបទល្មើស ហើយនៅពេលបញ្ជូនទៅតុលាការស្រាប់តែតុលាការមានការដោះលែង។ ត្រង់នេះ កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ កន្លងទៅ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានដាក់ចេញនូវយន្តការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី

ខេត្ត ដោយនៅក្នុងនោះ លោកបានគូសបញ្ជាក់ថា «**ការឃុំខ្លួនបណ្ដោះអាសន្ន គប្បីត្រូវបានប្រើប្រាស់សម្រាប់តែចំពោះបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមដែលមានភាពស្មុគស្មាញ និងធ្ងន់ធ្ងរ**»។ ម្យ៉ាងទៀត យើងត្រូវយកជ្រុងមួយដែលហួសពីជ្រុងក្នុងនាមជាជនរងគ្រោះ បើនិយាយពីសិទ្ធិមនុស្សវិញ គឺមនុស្សគ្រប់រូបមានសុទ្ធតែមានសេរីភាព តែសេរីភាពរបស់មនុស្សគឺត្រូវបានកម្រិតដោយច្បាប់។ ក្នុងពេលតែមួយយើងសួរថា រាល់ជនដែលប្រព្រឹត្តបទល្មើស សុទ្ធតែត្រូវបញ្ជូនទៅពន្ធនាគារទាំងអស់ឬ ទាំងដែលរឿងក្ដីខ្លះអត់គប្បីបញ្ជូនទៅពន្ធនាគារ ដូច្នេះរឿងដោះលែង ឬមិនដោះលែង គឺត្រូវផ្អែកទៅលើក្របខណ្ឌច្បាប់ទាំងអស់ ប៉ុន្តែប្រសិនបើ ដោះលែងមិនផ្អែកលើក្របខ័ណ្ឌច្បាប់ នោះគឺជាកំហុស។ អ្នកចេះច្បាប់ ត្រូវតែមើលក្នុងច្បាប់ ការឃុំខ្លួនគឺជាករណីលើកលែង លុះត្រាតែចាំបាច់បំផុតទើបត្រូវឃុំខ្លួន ហើយបើបុគ្គលនោះមានការធានាច្បាស់លាស់ មិនរត់គេចខ្លួនទៅទីណាទេ ព្រមទាំងហ៊ានប្រឈមមុខរាល់ការដោះស្រាយបញ្ហាទាំងអស់ ហេតុនេះ សំណួរសួរថា តើការឃុំខ្លួន មានភាពចាំបាច់ដែរឬទេ។ បន្ថែមពីលើនេះទៀត ប្រសិនបើរាល់អ្នកប្រព្រឹត្តខុសទាំងអស់ សុទ្ធតែត្រូវដាក់ចូលក្នុងពន្ធនាគារ នោះពន្ធនាគារច្បាស់ជាពេញចង្អៀត ដែលអាចត្រូវចំណាយថវិកាកសាងពន្ធនាគារបន្ថែមទៀត ទើបអាចដាក់ជនដែលប្រព្រឹត្តបទល្មើសទាំងនោះគ្រាន់។

ដូចនេះ ត្រូវប្រើយន្តការយុត្តិធម៌ព្រហ្មទណ្ឌបែបទំនើប ដែលត្រូវប្រើប្រាស់ភាពចាំបាច់បំផុតសម្រាប់ការឃុំខ្លួន ក្រៅពីនេះបើពុំចាំបាច់ទេគឺមិនត្រូវឃុំខ្លួនទេ ហើយម្យ៉ាងទៀត ក្នុងច្បាប់ក៏បានបញ្ញត្តិនូវការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដើម្បីជំនួសឱ្យវិធានការឃុំខ្លួន។

*«ក្រសួងយុត្តិធម៌. (២៥ តុលា ២០២១). សេចក្ដីណែនាំ លេខ០៣.កយ.សណន/២១.»*

*«ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌. (៩ មករា ២០២៤). ការឃុំខ្លួនបណ្ដោះអាសន្ន. ក្រសួងយុត្តិធម៌, (ទំព័រ Fresh News).»*

## កថាខណ្ឌទី២ ការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន មិនមែនជាវិធានការទូទៅនោះទេ ព្រោះការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានការនិរន្តរាយ ជំនួយឱ្យវិធានការនៃការឃុំខ្លួនបណ្ដោះអាសន្ន។ ជនត្រូវចោទ ត្រូវមានសេរីភាពដើម្បីមានលទ្ធភាពរៀបចំមធ្យោបាយការពារខ្លួននៅក្នុងនីតិវិធីច្បាប់។ ការឃុំខ្លួនបណ្ដោះអាសន្ន អាចធ្វើទៅបានតែក្នុងលក្ខខណ្ឌចាំបាច់ប៉ុណ្ណោះ។

ការឃុំខ្លួនបណ្ដោះអាសន្ន តាមលក្ខខណ្ឌនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា ត្រូវធ្វើឡើងតាមរយៈ៖

- ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និង
- ដីកាបង្គាប់ឱ្យឃុំខ្លួន របស់ចៅក្រមស៊ើបសួរ។

ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន គឺជាការសម្រេចដាក់ជនត្រូវចោទ ឱ្យនៅក្នុងការឃុំខ្លួនជាបណ្ដោះអាសន្នក្នុងរយៈពេលកំណត់ទៅតាមច្បាប់។ ចំណែកឯ ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជារបស់ចៅក្រមស៊ើបសួរទៅប្រធានពន្ធនាគារ ឬមន្ទីរឃុំខ្លួន ឱ្យទទួលនិងធ្វើការឃុំខ្លួនជនត្រូវចោទនោះនៅក្នុងពន្ធនាគារ ឬមន្ទីរឃុំខ្លួនដែលមន្ត្រីនោះកំពុងគ្រប់គ្រង។

ដូចនេះ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយទៅលើ(**២.១**).លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន និង(**២.២**). មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន។

### ២.១. លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្ន

ចៅក្រមស៊ើបសួរ អាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នជនត្រូវចោទណាម្នាក់បានតែក្នុងករណី៖

- អំពើដែលត្រូវបានស៊ើបសួរ ជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ ឆ្នាំ
- ការឃុំខ្លួន គឺជាការចាំបាច់
- ជនត្រូវចោទ មានអាយុតាមផ្លូវច្បាប់ ដែលអាចឃុំខ្លួនបាន។

### ២.២. មូលហេតុចាំបាច់នៃការឃុំខ្លួនបណ្ដោះអាសន្ន

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទបាន។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា បានចែងអំពីមូលហេតុនានាដែលបញ្ជាក់អំពីភាពចាំបាច់នៃការឃុំខ្លួននេះ។ ការឃុំខ្លួនបណ្ដោះអាសន្ន អាចត្រូវបានបង្គាប់កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់ ៖

១- ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

២- ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត

៣- ដើម្បីរក្សាភស្តុតាង ឬតម្រុយសម្ភារៈ

៤- ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

៥- ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ

៦- ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស។[22]

ច្បាប់មិនបានកំណត់ទេថា នៅក្នុងសំណុំរឿងមួយដែលកំពុងស៊ើបសួរ តើមានមូលហេតុប៉ុន្មានក្នុងចំណោមមូលហេតុទាំង ៦ ខាងលើត្រូវបំពេញ ដែលចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទបាននោះ តែខ្លឹមសារនេះ

[22] មាត្រា ២០៥ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អាចពន្យល់បានថា ឱ្យតែមានមូលហេតុយ៉ាងហោចណាស់មួយ គឺអាចបញ្ជាក់បានថា មានភាពចាំបាច់ដែលចៅក្រមស៊ើបសួរអាចធ្វើការសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន។

មួយវិញទៀត ទោះបីជាខ្លឹមសារនៃមូលហេតុក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្ននីមួយៗ មិនត្រូវបានពន្យល់នៅក្នុងច្បាប់ដោយផ្ទាល់ តែចៅក្រមស៊ើបសួរ និងបុគ្គលទូទៅអាចយល់បានក្នុងន័យនៃផលប្រយោជន៍សង្គម និងភាគីជាពិសេសការអនុវត្តគោលការណ៍ស្តីពី «ការសន្មតជាមុនថាគ្មានទោស ដរាបណាមិនទាន់មានសេចក្តីសម្រេចផ្តន្ទាទោសចូលជាស្ថាពរ» ឬគោលការណ៍ «សេរីភាពរបស់ជនត្រូវចោទ»។

### កថាខណ្ឌទី៣ នីតិវិធីនៃការសម្រេចឃុំខ្លួនបណ្តោះអាសន្ន

ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងអំឡុងពេលការបង្ហាញខ្លួនដំបូងរបស់ជនត្រូវចោទ ឬនៅដំណាក់កាលណាមួយផ្សេងទៀត នៅចំពោះមុខចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរ ដែលសម្រេចថានឹងឃុំខ្លួនបណ្តោះអាសន្ន ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទ។ ប្រសិនបើ ជនត្រូវចោទមានមេធាវីអម មេធាវីនោះ អាចបង្ហាញមធ្យោបាយការពារដល់កូនក្តីបាន។

ការកត់សម្គាល់ពីជនត្រូវចោទ និងការបង្ហាញមធ្យោបាយការពារដោយមេធាវីរបស់ជនត្រូវចោទ មានគោលបំណងដូចគ្នា ពោលគឺជាការជំទាស់ ព្រមទាំងការបង្ហាញហេតុផលក្នុងការជំទាស់ទៅនឹងចេតនានៃការសម្រេចឃុំខ្លួនរបស់ចៅក្រមស៊ើបសួរ ។

ក្នុងករណី ការពិភាក្សាដេញដោលអំពីការឃុំខ្លួនបណ្តោះអាសន្ន តាមការស្នើសុំនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងមានវត្តមានព្រះរាជអាជ្ញាផងនោះ ជាទូទៅនឹងឃើញមានជំហរផ្សេងគ្នាក្នុងការលើកឡើងរបស់ព្រះរាជអាជ្ញា និងជនត្រូវចោទ ព្រមទាំងមេធាវីរបស់គាត់ដែលក្នុងនោះ ៖

- ព្រះរាជអាជ្ញា លើកឡើងអំពីភាពចាំបាច់នៃការឃុំខ្លួន ដោយបញ្ជាក់អំពីមូលហេតុណាមួយ ឬច្រើនដូចបានបកស្រាយខាងលើ (នៅក្នុងកថាខណ្ឌទី១ ចំណុច១.២.មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) ដែលបង្ហាញអំពីភាពចាំបាច់នោះ
- ជនត្រូវចោទ ឬ/និងមេធាវីការពារក្តី លើកឡើងអំពីភាពមិនចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្ន ដោយបញ្ជាក់ មូលហេតុមួយ ឬច្រើនដែលព្រះរាជអាជ្ញាលើកឡើងដើម្បីស្នើសុំឃុំខ្លួននោះ ។

នៅរាល់ការលើកឡើងរបស់ព្រះរាជអាជ្ញា និងជនត្រូវចោទ ឬមេធាវីការពារក្តី ត្រូវតែមាននូវយុត្តិកម្ម (Justification) សម្រាប់គាំទ្រនូវហេតុផលនីមួយៗ និងដើម្បីឱ្យចៅក្រមស៊ើបសួរយល់តាម និងជឿជាក់។

ដោយឡែក ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទករណីមួយចំនួន ត្រូវធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ (គ្មានការស្នើពីព្រះរាជអាជ្ញា)។ ក្នុងករណីនេះ ក្នុងពេលពិភាក្សាដេញដោល ការលើកឡើងជំទាស់របស់ជនត្រូវចោទ និងមេធាវីការពារក្តី អំពីបំណងនៃការឃុំខ្លួន គឺជាការលើកឡើងជាទូទៅដោយហេតុថា មិនមានការបញ្ជាក់ច្បាស់លាស់ជាមុនអំពីមូលហេតុមួយ ឬច្រើនឱ្យជនត្រូវចោទ ឬមេធាវីការពារក្តីបានដឹងជាមុននោះទេ។

ក្នុងករណីខ្លះដែលអាច ឬបានកើតឡើងចំពោះករណីមួយចំនួន ចៅក្រមស៊ើបសួរបានកោះហៅជនត្រូវចោទឱ្យចូលឆ្លើយ ហើយចៅក្រមបានចេញដីកាសម្រេចឃុំខ្លួនជនត្រូវចោទភ្លាម បន្ទាប់ពីឆ្លើយសម្រាប់ធ្វើកំណត់ហេតុនោះដោយមិនមានការពិភាក្សាដេញដោលអំពីការឃុំខ្លួន ឬមិនឃុំខ្លួន ឬពេលខ្លះជនត្រូវចោទមិនទាំងដឹងខ្លួនជាមុនផង។ ការណ៍នេះទំនងថា ការកោះហៅឱ្យចូលឆ្លើយ គ្រាន់តែជាហេតុផលបន្ទាប់បន្សំប៉ុណ្ណោះ ដោយឡែក ចេតនាឃុំខ្លួនជនត្រូវចោទ អាចជាបំណងសំខាន់ទុកជាមុនរបស់ចៅក្រមស៊ើបសួរ

### ៣.១. បង្គាប់ឱ្យឃុំខ្លួន

ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មិនមាននូវអានុភាពពេញលេញដើម្បីឱ្យជនត្រូវចោទនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនទេ ពោលគឺចៅក្រមស៊ើបសួរ ត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួនដោយឡែកមួយទៀតជាចាំបាច់។ ដីកាបង្គាប់ឱ្យឃុំខ្លួន ត្រូវមានចុះនិទ្ទេសដូចខាងក្រោម ៖

- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គលដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតដល់ពេលបានទទួលការឱ្យដំណឹងអំពីការដោះលែងជនត្រូវចោទឱ្យមានសេរីភាពឡើងវិញ។[23]

### ៣.២. ការអនុវត្តជាក់ស្តែងមួយចំនួនអំពីការឃុំខ្លួនបណ្តោះអាសន្ន

អ្នកច្បាប់ទាំងអស់ទទួលស្គាល់ខ្លឹមសារច្បាប់ និងលក្ខខណ្ឌស្តីពីការឃុំខ្លួនបណ្ដោះអាសន្ន។ បញ្ហាចំនួន ២ (ពីរ) ដូចខាងក្រោម ត្រូវបានលើកឡើងក្នុងបញ្ញត្តិច្បាប់៖

- គោលការណ៍សេរីភាព ដែលមានន័យថា ជាគោលការណ៍ជនត្រូវចោទត្រូវនៅក្រៅឃុំ ឬ មានសេរីភាព
- ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។

ពាក្យ «គោលការណ៍សេរីភាព» និងពាក្យ «ក្នុងករណីចាំបាច់» នេះ ត្រូវពន្យល់ និងបកស្រាយ ទៅតាមគោលបំណងរបស់ច្បាប់ និងទំនៀមទម្លាប់នៃការអនុវត្តក្នុងនីតិវិធីព្រហ្មទណ្ឌ ហើយមិនត្រូវមានការស្មុគស្មាញដែរ។ តែពេលខ្លះ ការអនុវត្តមួយចំនួនមានការខុសឆ្គង ដែលការខុសឆ្គងនេះ អាចមានឥទ្ធិពលមកពីកត្តាមនុស្ស កត្តាផលប្រយោជន៍ និងឥទ្ធិពលពីខាងក្រៅ។ នៅពេលមានបណ្ដឹងព្រហ្មទណ្ឌកើតឡើង ទាំងនៅមន្ត្រីនគរបាលយុត្តិធម៌ នៅអយ្យការ និងនៅចៅក្រមស៊ើបសួរ ទំនងថា ជនសង្ស័យ ឬជនត្រូវចោទតែងស្ថិតនៅក្នុងស្ថានភាពហានិភ័យខ្ពស់ជាទូទៅ បើទោះបីជាបុគ្គលរូបនេះមានជាប់ពាក់ព័ន្ធឬមិនជាប់ពាក់ព័ន្ធនឹងបទល្មើសក្តី ឬអង្គហេតុនៃរឿងក្តីជាប្រភេទរឿងក្តីរដ្ឋប្បវេណីក៏ដោយ។

[23] មាត្រា ២២១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជនត្រូវចោទ ទាំងក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ជាច្រើនត្រូវបានសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលករណីខ្លះការឃុំខ្លួននោះ អាចហួសពីគោលបំណងរបស់ច្បាប់ និងហួសពីការចាំបាច់។ ជាច្រើនឆ្នាំកន្លងមកនេះ ដោយសារតែចំនួនបទល្មើសព្រហ្មទណ្ឌបានកើតឡើងច្រើន ការឃុំខ្លួនក៏មានចំនួនច្រើនបណ្តាលឱ្យហេតុការណ៍ចំនួន ៣ កើតឡើង៖

- ភាពចង្អៀត ណែនតាន់តាប់នៃអ្នកជាប់ឃុំនៅពន្ធនាគារ និងមណ្ឌលឃុំខ្លួនជាច្រើន ពិសេសនៅរាជធានីភ្នំពេញ ហួសពីលទ្ធភាពនៃការផ្ទុក
- យុទ្ធនាការនៃការជំរុញនីតិវិធីនៃសំណុំរឿងព្រហ្មទណ្ឌ ពិសេសពាក់ព័ន្ធនឹងអ្នកជាប់ឃុំ ឱ្យដំណើរការទៅមុខលឿន ដែលអនុវត្តដោយក្រសួងយុត្តិធម៌
- ក្រសួងយុត្តិធម៌ ដោយមានការសហការជាមួយការិយាល័យឧត្តមស្នងការជាន់ខ្ពស់ទទួលបន្ទុកសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា បានរៀបចំគំរូ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលចៅក្រមស៊ើបសួរទូទាំងប្រទេសត្រូវយកមកអនុវត្ត ហើយគំរូថ្មីនេះ តម្រូវឱ្យចៅក្រមស៊ើបសួរ លើកឡើងកាន់តែច្បាស់នូវសំអាងហេតុ ឬហេតុផលនៃការឃុំខ្លួនបណ្តោះអាសន្ន ជាជាងគ្រាន់តែគូស (គ្រីស) ឃ្លានៃមូលហេតុនៃការឃុំខ្លួន ដែលមានស្រាប់នៅក្នុងដីកានោះ។

ការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ហួសពីការចាំបាច់ដែលមានចែងក្នុងច្បាប់ គឺប៉ះពាល់ដល់ករណីជាច្រើនដូចជា ៖

- គោលការណ៍សន្មតជាមុនថាគ្មានទោស និងគោលការណ៍សេរីភាពរបស់ជនត្រូវចោទ ដែលបណ្តាលឱ្យប៉ះពាល់សិទ្ធិ ផលប្រយោជន៍របស់គាត់ ពិសេសការរៀបចំមធ្យោបាយការពារខ្លួន និងការទំនុកបម្រុងជីវភាពគ្រួសារ
- ជាបន្ទុករបស់រដ្ឋ ដែលត្រូវចំណាយ ក្នុងពេលបុគ្គលនោះត្រូវជាប់ឃុំខ្លួន
- ភាពណែនតាន់តាប់ និងការមិនមានលទ្ធភាពទទួលផ្ទុកជនត្រូវចោទដែលមានចំនួនច្រើន
- ខាតបង់កម្លាំងពលកម្ម ដែលអាចមានប្រយោជន៍ដល់សង្គម។

## ផ្នែកទី២ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

### កថាខណ្ឌទី១ ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន និងអនីតិជន

ការឃុំខ្លួនបណ្តោះអាសន្ន គឺជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌ ស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ ការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងបានក្នុង

ករណីមានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំឡើងទៅ។[24]

ជាទូទៅការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមរយៈគំនិតផ្តើមពីចៅក្រមស៊ើបសួរ ឬតាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណា ការស្វែងយល់ដោយផ្ទាល់ទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឬស្ថានភាពជាក់ស្តែងនៃបទល្មើសដែលបានប្រព្រឹត្ត។

នៅពេលដែលចៅក្រមស៊ើបសួរសម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន នោះគឺត្រូវធ្វើឡើងតាមរយៈ «ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន» ដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ចំពោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ដាច់ដោយឡែកពីគ្នាទៅតាមស្ថានភាពនៃជនត្រូវចោទ (នីតិជន ឬអនីតិជន) ឬលក្ខណៈនៃបទល្មើស (បទមជ្ឈិម ឬបទឧក្រិដ្ឋ)។

ការកំណត់ថិរវេលាដាច់ដោយឡែកពីគ្នារវាងនីតិជន និងអនីតិជន យើងនឹងធ្វើការបកស្រាយក្នុងចំណុច (១.១.) ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន និង (១.២.) ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន។

### ១.១. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះនីតិជន

ចៅក្រមស៊ើបសួរ ធ្វើការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្នតាមដីកាដោយមានភ្ជាប់សំអាងហេតុ ក្នុងដីកានេះត្រូវយោងទៅលើមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានបញ្ញត្តិក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងត្រូវគោរពនូវរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នដែលកំណត់ដោយច្បាប់។

ចំពោះបទឧក្រិដ្ឋ ប្រសិនបើនីតិជន ដែលត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវមានថិរវេលាមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ ដោយបូកបញ្ចូលជាមួយរយៈពេលនៃការឃាត់ខ្លួនផង ប្រសិនបើមាន។ ប៉ុន្តែ នៅពេលផុតថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនម្តងបាន ៦ (ប្រាំមួយ) ខែ ដោយដីកា សម្រេចមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរ អាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ (ពីរ) ដងគត់។[25]

ចំពោះបទមជ្ឈិម ប្រសិនបើនីតិជន ដែលត្រូវបានចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវមានថិរវេលាមិនអាចលើសពី ៤ (បួន) ខែបានទេ។ ទោះបីជាយ៉ាងណា នៅពេលផុតថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះ ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែម្តងគត់ និងមិនឱ្យលើសរយៈពេល ២ (ពីរ) ខែ

[24] មាត្រា ២០៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[25] មាត្រា ២០៨ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។[26]

ចំពោះចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលឧក្រិដ្ឋកម្មធ្ងន់ធ្ងរ សម្តៅទៅលើ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (Crime Against Humanity), ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (Crime of Genocide) និងឧក្រិដ្ឋកម្មសង្គ្រាម (War Crime) ។ ការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរខាងលើ ត្រូវមានចិរវេលាយ៉ាងយូរ ១ (មួយ) ឆ្នាំ។ ប៉ុន្តែនៅពេលផុតចិរវេលានៃការឃុំខ្លួននេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្ន ម្តងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ហើយចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់។[27]

### ១.២. ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន

ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជន ការឃុំខ្លួនបណ្តោះអាសន្ន មិនគួរអនុវត្តចំពោះអនីតិជនទាំងអស់នោះឡើយ ហើយជម្រើសដែលល្អបំផុត គឺការប្រគល់អនីតិជននោះទៅមណ្ឌលសង្គមកិច្ច ឬទីតាំងផ្សេងទៀតដែលទទួលស្គាល់ដោយច្បាប់ក្នុងការទទួលការថែទាំ និងផ្តល់ការអប់រំជំនួសវិញ។ អនុវត្តដូច្នេះ ព្រោះតែអនីតិជន គឺជាបុគ្គលដែលត្រូវទទួលការអប់រំ ការថែទាំ និងការការពារ ជាជាងដាក់ក្នុងពន្ធនាគារឬមណ្ឌលឃុំខ្លួន។

លើសពីគោលការណ៍សេរីភាពដែលអនុវត្តចំពោះជនត្រូវចោទទូទៅ ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ក៏គួរតែជាលក្ខខណ្ឌកម្រ ហើយដែលអាចអនុវត្តបាន ត្រូវតែស្ថិតក្នុងស្ថានភាពចាំបាច់បំផុត ដែលត្រូវបានចោទប្រកាន់អាចត្រូវឃុំខ្លួន ឬមិនអាចឃុំខ្លួនបណ្តោះអាសន្ន អាស្រ័យលើយុវភាពរបស់គាត់។

ចំពោះអនីតិជន ដែលមានអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្ននោះទេ។ ចៅក្រមស៊ើបសួរ អាចសម្រេចប្រគល់អនីតិជននេះឱ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។[28]

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន មានដូចតទៅ៖

- ប្រសិនបើអនីតិជន ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ គឺការឃុំខ្លួនបណ្តោះអាសន្ន ត្រូវមានចិរវេលាមិនអាចលើសពី ៤ (បួន) ខែបានទេ។

[26] មាត្រា ២០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[27] មាត្រា ២១០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[28] មាត្រា ២១២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

- ប្រសិនបើអនីតិជន ដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវមានថិរវេលាមិនអាចលើសពី ៦ (ប្រាំមួយ) ខែបានទេ។[29]

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ៖

- ប្រសិនបើអនីតិជន ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ គឺការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវមានថិរវេលាមិនអាចលើសពី ២ (ពីរ) ខែបានទេ។
- ប្រសិនបើអនីតិជន ដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ គឺការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវមានថិរវេលាមិនអាចលើសពី ៤ (បួន) ខែបានទេ។

អាយុនេះ ត្រូវគិតត្រឹមពេលដែលបទល្មើសបានកើតឡើង។ ដោយឡែក ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ សម្រាប់អនីតិជននោះឡើយ។[30] ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នលើអនីតិជន មិនអាចត្រូវបាន ពន្យារពេលបានទេ បើពុំនោះទេ ត្រូវដោះលែងអនីតិជននោះឱ្យមានសេរីភាព។

## កថាខណ្ឌទី២ នីតិវិធីនៃការពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្ន

### ២.១. ការពន្យារពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន

កាលណាចៅក្រមស៊ើបសួរសម្រេចថា ពន្យារពេលឃុំខ្លួនជាបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជននេះ។ កាលណាជនត្រូវចោទមានមេធាវីអម នោះមេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួនកូនក្ដីរបស់ខ្លួន។

ចៅក្រមស៊ើបសួរ ពន្យារការឃុំខ្លួនបណ្ដោះអាសន្ន តាមដីកាដោយមានសំអាងហេតុ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរ ត្រូវយោងទៅតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយដីកានេះត្រូវឱ្យដំណឹងជាបន្ទាន់ដល់ជនត្រូវចោទ។ ដោយឡែក ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចពន្យារបានទេ កាលណាលក្ខខណ្ឌមានដូចខាងក្រោម៖

- ជនត្រូវចោទជាអនីតិជន
- ការពន្យារការឃុំខ្លួនបណ្ដោះអាសន្ន នឹងបណ្ដាលឱ្យថិរវេលានៃការឃុំខ្លួននោះលើសពីពាក់កណ្ដាលអប្បបរមានៃទោសចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់។

[29] មាត្រា ២១៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា ២១៤ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំពោះនីតិជន ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន អាចប្រព្រឹត្តទៅបានដោយអាស្រ័យទៅលើប្រភេទបទល្មើសដូចខាងក្រោម ៖

- ចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ ដែលមានរួមមាន បទឧក្រិដ្ឋសង្គ្រាម បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទក្រិដ្ឋប្រល័យពូជសាសន៍ គឺចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្ន ម្តងបាន ១ (មួយ) ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ២ (ពីរ) ដងគត់
- ចំពោះបទឧក្រិដ្ឋ ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួនម្តងបាន ៦ (ប្រាំមួយ) ខែ ដោយដីកា សម្រេចមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរ អាចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ (ពីរ) ដងគត់
- ចំពោះបទមជ្ឈិម ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានតែម្តងគត់ និងមិនឱ្យលើសរយៈពេល ២ (ពីរ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

### ២.២. ការអនុវត្តកិច្ចនៃការពន្យារពេលឃុំខ្លួន

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មិនបានកំណត់អំពីនីតិវិធីជាក់លាក់ទាក់ទងនឹងការពន្យារពេលនៃការឃុំខ្លួននេះទេ ពោលគឺបានត្រឹមតែតម្រូវឱ្យចៅក្រមស៊ើបសួរ ឱ្យដំណឹងទៅជនត្រូវចោទ ដើម្បីទទួលការកត់សម្គាល់របស់ជនត្រូវចោទ និងមធ្យោបាយការពារពីមេធាវីរបស់ជនត្រូវចោទប៉ុណ្ណោះ ដោយមិនបានកំណត់រយៈពេលដែលត្រូវដាក់ការកត់សម្គាល់ ឬមធ្យោបាយការពារមុនពេលចេញដីកាសម្រេចពន្យារការឃុំខ្លួនឡើយ។

ហេតុនេះចៅក្រមស៊ើបសួរ អាចអនុវត្តកិច្ចនីតិវិធីខុសៗគ្នា ដោយខុសគ្នា នៅត្រង់ថា៖

- ចៅក្រមស៊ើបសួរខ្លះ បានជូនដំណឹងអំពីបំណងនៃការពន្យារការឃុំខ្លួនបណ្តោះអាសន្នជាមុន ហើយជនត្រូវចោទ និងមេធាវី អាចធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរជំទាស់នឹងបំណងនៃការពន្យារការឃុំខ្លួននោះ។
- ចៅក្រមស៊ើបសួរខ្លះ ចេញដីកាសម្រេចពន្យារការឃុំខ្លួនមុនពេល ដែលលិខិតជូនដំណឹងមកដល់ជនត្រូវចោទ និងមេធាវីការពារក្តី ដែលហេតុនេះ ទាំងជនត្រូវចោទ ទាំងមេធាវីការពារក្តី មិនមានលទ្ធភាពក្នុងការជំទាស់ ឬដាក់មធ្យោបាយការពារប្រឆាំងនឹងបំណងពន្យារការឃុំខ្លួនបណ្តោះអាសន្នជាមុនទេ។

ប្លែកពីការអនុវត្តខាងលើ នៅសាលាក្តីខ្មែរក្រហម មុនចេញដីកាសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្ន សហចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងទៅជនត្រូវចោទ និងមេធាវីការពារក្តី និងទុករយៈពេល ១៥ ថ្ងៃសម្រាប់ឱ្យជនត្រូវចោទ និងមេធាវីការពារក្តី ធ្វើការប្តឹងតវ៉ានឹងចេតនានៃការពន្យារពេលឃុំខ្លួននោះមកសហចៅក្រមស៊ើបសួរ។ ដោយហេតុនេះ

មេធាវីការពារក្តីបានដាក់សារណាជាលាយលក្ខណ៍អក្សរដោយមានហេតុផលជាច្រើន ដែលថាការបន្តការឃុំខ្លួនមិនមានការចាំបាច់តទៅទៀត មុននឹងសហចៅក្រមស៊ើបសួរ ចេញដីកាសម្រេចអំពីការពន្យារការឃុំខ្លួននោះ។

## ផ្នែកទី៣ សិទ្ធិត្រូវបានការពារ និងតំណាងដោយមេធាវី

### កថាខណ្ឌទី១ សិទ្ធិមានមេធាវីតំណាង

#### ១.១. សិទ្ធិមានមេធាវី

ដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទមានសិទ្ធិមានមេធាវីអមនៅគ្រប់កិច្ចនីតិវិធីរបស់ចៅក្រមស៊ើបសួរ។ សិទ្ធិមានមេធាវីអមនេះ គឺស្ថិតក្នុងបរិបទខុសគ្នា រវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចចាត់តាំងមេធាវីឱ្យតំណាងខ្លួននៅក្នុងនីតិវិធី ដោយមេធាវីតំណាងនោះមានសិទ្ធិផ្តល់ចម្លើយ និងទាមទារសំណងរដ្ឋប្បវេណីជំនួស និងជាប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងទស្សនទានច្បាប់ ដើមបណ្តឹងរដ្ឋប្បវេណី មានមេធាវីតំណាងក៏បាន ឬមិនមានក៏បាន តាមការជ្រើសរើសរបស់គាត់ ដោយច្បាប់មិនបានតម្រូវឱ្យត្រូវតែមានមេធាវីនោះទេ ហើយតុលាការក៏មិនមានកាតព្វកិច្ចផ្តល់ជូនមេធាវីតំណាងនេះដែរ។ ទម្រង់នេះ ខុសពីការអនុវត្តនៅសាលាក្តីខ្មែរក្រហម ដែលដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានរៀបចំឱ្យមានមេធាវីតំណាងដោយឥតយកកម្រៃ ហើយមេធាវីទាំងអស់នោះត្រូវបានសម្របសម្រួល និងដឹកនាំដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលតំណាងឱ្យផលប្រយោជន៍រួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់។ ដោយឡែក ជនត្រូវចោទ មិនអាចចាត់តាំងមេធាវីឱ្យតំណាងខ្លួនបានទេ តែជាមេធាវីការពារសិទ្ធិ ឬការពារក្តី ជាប្រយោជន៍ដល់ជនត្រូវចោទនោះ។ សិទ្ធិមានមេធាវីការពារក្តីរបស់ជនត្រូវចោទមានភាពខុសប្លែកគ្នាខ្លះអាស្រ័យលើយុវភាពរបស់ជនត្រូវចោទ ដែលជាអនីតិជន ឬអនីតិជន ព្រមទាំងប្រភេទបទល្មើស ដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិម។

ចំពោះដើមបណ្តឹងរដ្ឋប្បវេណីចាត់តាំងមេធាវីរបស់ខ្លួន តាមរយៈការធ្វើ «លិខិតប្រគល់សិទ្ធិតំណាង»។ ការធ្វើលិខិតប្រគល់សិទ្ធិតំណាងនេះ គឺដើម្បីចាត់តាំងមេធាវីនោះឱ្យតំណាងគាត់នៅក្នុងការឆ្លើយបំភ្លឺ ការតតាំង ការទាមទារសំណងរដ្ឋប្បវេណី និងអនុវត្តសិទ្ធិដទៃទៀតតាមការអនុញ្ញាតរបស់ច្បាប់។ ក្នុងករណីដែល ជនរងគ្រោះជាអនីតិជន ឬជនដែលមានវិបល្លាសស្មារតី ឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះ គឺជាអ្នកប្រគល់សិទ្ធិតំណាង។ ចំណែកឯជនត្រូវចោទ ចាត់តាំងមេធាវីការពារក្តីឱ្យខ្លួនតាមរយៈ «ពាក្យសុំពឹងពាក់មេធាវី»។ មេធាវីដែលត្រូវបានចាត់តាំងនេះ មិនមែនអនុវត្តសិទ្ធិតំណាងឱ្យជនត្រូវចោទឡើយ តែគឺជាការការពារសិទ្ធិ និងផលប្រយោជន៍របស់ជនត្រូវចោទ។ ប្រហាក់ប្រហែលនឹងដើមបណ្តឹងរដ្ឋប្បវេណីដែរ ក្នុងករណីដែលជនត្រូវចោទជាអនីតិជន ឬជនមានវិបល្លាសស្មារតី ឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះ គឺជាអ្នកសុំពឹងពាក់មេធាវី។

ក្រោយពីទទួលបានការប្រគល់សិទ្ធិ ឬការពឹងពាក់មេធាវី មេធាវីពាក់ព័ន្ធ ត្រូវធ្វើពាក្យសុំតំណាង ឬសុំការពារក្តីទៅចៅក្រមស៊ើបសួរ ដើម្បីទទួលបានសិទ្ធិពេញលេញក្នុងការតំណាង ឬការពារក្តីជាប្រយោជន៍កូនក្តីរបស់ខ្លួនដោយភ្ជាប់

ជាមួយនឹងលិខិតប្រគល់សិទ្ធិតំណាង ឬពាក្យសុំពឹងពាក់មេធាវី។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី គឺជាវិធានគោល ដែលចែងអំពីសិទ្ធិរបស់ភាគីក្នុងការមានមេធាវីអមព្រមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់មេធាវីនៅក្នុងនីតិវិធីព្រហ្មទណ្ឌ។ ដោយឡែកអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងពេលសួរចម្លើយ ដោយចៅក្រមស៊ើបសួរមានន័យថា ច្បាប់បានតម្រូវលក្ខខណ្ឌ ដែលជាកាតព្វកិច្ចក្នុងការមានមេធាវីការពារសិទ្ធិឱ្យអនីតិជននៅក្នុងដំណាក់កាលនេះ។ មេធាវី អាចត្រូវបានជ្រើសរើសដោយអាណាព្យាបាល របស់អនីតិជននោះផ្ទាល់ ឬតាមរយៈការចាត់តាំង ដែលអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ នៅដំណាក់កាលជំនុំជម្រះ ករណីបទឧក្រិដ្ឋ ទោះបីបុគ្គលនោះជានីតិជន ឬអនីតិជនយ៉ាងណាក្តី បុគ្គលនោះត្រូវតែមានមេធាវីការពារសិទ្ធិជាចាំបាច់ ដែលជាលក្ខខណ្ឌចាប់បង្ខំ។ ប្រសិនបើជនជាប់ចោទនោះមិនបានចាត់តាំងមេធាវីតាមការជ្រើសរើសរបស់ខ្លួនទេ តុលាការនឹងសម្របសម្រួលឱ្យមានការចាត់តាំងមេធាវីដោយឥតយកប្រាក់កម្រៃ តាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ក្នុងដំណាក់កាលនៃចៅក្រមស៊ើបសួរ មេធាវីការពារក្តី អាចអនុវត្តសិទ្ធិ និងកាតព្វកិច្ចមួយចំនួនដូចខាងក្រោម៖

- ចូលរួមអមកូនក្តី និងស្តាប់ នៅពេលកូនក្តីនោះត្រូវសួរចម្លើយ ឬនីតិវិធីសួរតទល់ ដោយចៅក្រមស៊ើបសួរ លើកលែងតែករណីដូចមានចែងនៅមាត្រា ១៤៥ កថាខណ្ឌទី ៣ និងទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- សួរសំណួរទៅកូនក្តី ឬ/និង ភាគីផ្សេងទៀត ឬ/និងសាក្សី ដោយមានការយល់ព្រមពីចៅក្រមស៊ើបសួរនៅក្នុងនីតិវិធីសួរចម្លើយ ឬ/និងសួរតទល់
- ចូលរួមអម និងស្តាប់ ការស្តាប់ចម្លើយកូនក្តីដោយអ្នកជំនាញ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ លើកលែងតែកាលណាចៅក្រមស៊ើបសួរចាត់តាំងគ្រូពេទ្យ ឬអ្នកចិត្តសាស្ត្រ ដើម្បីពិនិត្យជនត្រូវចោទ នោះការពិនិត្យវេជ្ជសាស្ត្រ ឬចិត្តសាស្ត្រ ត្រូវធ្វើដោយគ្មានវត្តមានមេធាវី[31]
- ដាក់សំណើសុំបញ្ចូលភស្តុតាងទៅក្នុងសំណុំរឿង
- ដាក់ការស្នើសុំឱ្យបំពេញកិច្ចនានា
- ប្រាស្រ័យទាក់ទងជាមួយកូនក្តីដែលនៅក្នុងពន្ធនាគារក្រោមការឃុំខ្លួនបណ្តោះអាសន្ន ដោយមានសិទ្ធិជួបពិភាក្សា ផ្តល់ពត៌មាន និងអានឯកសារសំណុំរឿងឱ្យស្តាប់ ក្នុងលក្ខខណ្ឌសម្ងាត់ និងមិនមានការរំខាន
- ទទួលការជូនដំណឹងអំពីពត៌មានទាំងអស់ ក្នុងលក្ខខណ្ឌ ដែលច្បាប់កំណត់ឱ្យចៅក្រមស៊ើបសួរជូនដំណឹងទៅជនត្រូវចោទ
- មានសិទ្ធិជូនសំណើសុំជំនួយពីអ្នកបកប្រែ អ្នកជំនាញ ព្រមទាំងអនុវត្តសិទ្ធិផ្សេងទៀតដែលផ្តល់ឱ្យដោយច្បាប់នៅក្នុងកិច្ចរបស់ចៅក្រមស៊ើបសួរ។

ក្រៅពីជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បុគ្គលដែលស្ថិតនៅក្រៅនីតិវិធីស៊ើបសួរ ក៏អាចពឹងពាក់មេធាវីធ្វើជាតំណាងក្នុងការដាក់ពាក្យសុំឱ្យសងនូវវត្ថុដែលចាប់យកត្រឡប់មកវិញផងដែរ។

[31] មាត្រា ១៦៧ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ១.២. សិទ្ធិរបស់ជនត្រូវចោទជាអនីតិជន

អនីតិជន គឺជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ។ ផ្អែកតាមលិខិតូបករណ៍អន្តរជាតិ គឺអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ បានចែងនូវគោលការណ៍ណែនាំ ៤ ហើយតាមរយៈនេះ សិទ្ធិកុមារដែលជាអនីតិជនត្រូវទទួលបានការការពារ ។ ចំពោះគោលការណ៍ទាំង ៤ នេះ រួមមាន៖

**១-ឧត្តមប្រយោជន៍កុមារ** គឺនៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ ទោះធ្វើឡើងដោយស្ថាប័នឯកជន ឬសាធារណៈទទួលភារៈខាងសុខុមាលភាពសង្គម ឬដោយតុលាការ ឬអាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែយកចិត្តទុកដាក់ជាចម្បង។[32]

**២-ការមិនរើសអើង** គឺកុមារគ្រប់រូបត្រូវទទួលបាននូវសិទ្ធិទាំងអស់របស់ខ្លួន ដោយមិនមានការរើសអើងនៃប្រភេទណាមួយទេ។ កុមារ មិនអាចត្រូវបានគេបដិសេធសិទ្ធិរបស់ខ្លួន ដោយសារតែជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ទស្សនៈ នយោបាយ ឬទស្សនៈផ្សេងៗ ប្រភពជនជាតិ ឬឋានៈក្នុងសង្គម ទ្រព្យសម្បត្តិ ពិការភាព កំណើត ឋានៈ ឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬ ឪពុកម្តាយរបស់កុមារនោះទេ។[33]

**៣-សិទ្ធិរស់រានមានជីវិត និងសិទ្ធិអភិវឌ្ឍន៍** គឺកុមារគ្រប់រូប មានសិទ្ធិមានជីវិតតាំងពីកំណើត។ រដ្ឋត្រូវធានាពីការរស់រានមានជីវិត និងការអភិវឌ្ឍន៍របស់កុមារ ឱ្យមានកំរិតអតិបរមាតាមដែលអាចធ្វើបាន។[34]

**៤-ការគោរពទស្សនៈកុមារ** គឺកុមារដែលមានសមត្ថភាពបង្កើតទស្សនៈផ្ទាល់ខ្លួន នូវសិទ្ធិបញ្ចេញទស្សនៈទាំងនោះដោយសេរី លើគ្រប់បញ្ហាពាក់ព័ន្ធនឹងកុមារ។ ទស្សនៈទាំងនេះរបស់កុមារ ត្រូវបានគេយកទៅពិចារណាថ្លឹងថ្លែងដោយគិតទៅតាមវ័យ និងភាពចាស់ទុំរបស់កុមារ មានន័យថាឱ្យបានសមស្របទៅតាមអាយុ និងការយល់ដឹងរបស់កុមារ។

បន្ថែមពីលើនេះទៀត អនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ ក៏មានចែងផងដែរនូវសិទ្ធិជាក់លាក់របស់កុមារ។ ចំពោះសិទ្ធិជាក់លាក់នេះ បែងចែកជាបួនប្រភេទធំៗនៃសិទ្ធិកុមារ រួមមាន៖

**១-សិទ្ធិរស់រានមានជីវិត៖** សិទ្ធិនេះរួមបញ្ចូលទាំងសិទ្ធិមានជីវិត និងសិទ្ធិទទួលបានការថែទាំសុខភាព និងវេជ្ជសាស្ត្រក្នុងកំរិតខ្ពស់បំផុត។

**២-សិទ្ធិអភិវឌ្ឍន៍៖** សិទ្ធិទាំងនេះរួមបញ្ចូលអ្វីទាំងអស់ ដែលកុមារត្រូវការដើម្បីលូតលាស់ក្នុងកំរិតខ្ពស់បំផុត និងដើម្បីឱ្យក្លាយទៅជាសមាជិកដែលទទួលខុសត្រូវរបស់សង្គម។ សិទ្ធិនេះ រួមមានការអប់រំគ្រប់ប្រភេទ និងសិទ្ធិ ទទួលបានជីវភាពរស់នៅគ្រប់គ្រាន់ សម្រាប់ការលូតលាស់របស់កុមារ ផ្នែករាងកាយ សតិអារម្មណ៍ ស្មារតី សីលធម៌ និងសង្គម។

[32] មាត្រា ៣ កថាខណ្ឌទី១ នៃអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ

[33] មាត្រា ២ នៃអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ

[34] មាត្រា ៦ នៃអនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ

**៣-សិទ្ធិទទួលបាននូវការការពារ៖** សិទ្ធិនេះ ចង់សំដៅយ៉ាងទូលាយដល់សិទ្ធិដែលត្រូវបានទទួលការការពារ រួចផុតពីអំពើ និងការប្រព្រឹត្តផ្សេងៗ ដែលបង្កអន្តរាយដល់កុមារ។ សិទ្ធិនេះ រួមមានការការពារពីការរើសអើង ពីការរំលោភបំពាន ការទុកចោលមិនយកចិត្តទុកដាក់ និងការកេងប្រវ័ញ្ច ការការពារកុមារដែលគ្មានគ្រួសារ និងការការពារកុមារជាជនភៀសខ្លួន។

**៤-សិទ្ធិចូលរួម៖** សិទ្ធិទាំងនេះ គ្របដណ្តប់លើសិទ្ធិរបស់កុមារក្នុងការចូលរួមបញ្ចេញមតិរបស់ខ្លួនក្នុងគ្រប់បញ្ហា និងត្រូវបានគេស្តាប់ក្នុងគ្រប់សេចក្តីសម្រេចដែលប៉ះពាល់ដល់អាយុជីវិតរបស់កុមារ។ នៅពេលសមត្ថភាពរបស់កុមាររីកចំរើនឡើង កុមារគួរតែមានឱកាសកាន់តែច្រើនជាងមុន ក្នុងការចូលរួមសកម្មភាពរបស់សង្គម ដើម្បីជាការរៀបចំសម្រាប់ជីវិតជាមនុស្សពេញវ័យ។

ដោយឡែកនៅក្នុងបទដ្ឋានគតិយុត្តជាតិ ដូចជា រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៤៨ បានបញ្ញត្តិផងដែរថា រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពី កុមារជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណ លើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬ ដែលនាំអោយអន្តរាយដល់សុខភាព ឬ សុខុមាលភាពរបស់កុមារ។[35] ចំណែកច្បាប់ស្តីពី យុត្តិធម៌អនីតិជន ក៏បានការពារនូវសិទ្ធិរបស់អនីតិជនដែលជាជនត្រូវចោទផងដែរ ដោយបញ្ញត្តិថា អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចជា ៖ សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី, សិទ្ធិមិនទទួលការបង្ខិតបង្ខំឱ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង, សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន, សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល, សិទ្ធិទទួលបានការឱ្យដំណឹងអំពីបទចោទប្រកាន់, សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់, សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី, សិទ្ធិឱ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន, សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់, សិទ្ធិបង្ហាញភស្តុតាង, សិទ្ធិស្នើសុំឱ្យកោះហៅសាក្សី និងសួរសាក្សី, សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ, សិទ្ធិស្នើសុំឱ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ, សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស ព្រមទាំងសិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។[36]

---

[35] មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[36] មាត្រា ៦ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ដើម្បីគោរពសិទ្ធិឯកជនរបស់អនីតិជន គឺការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ហើយមានតែបុគ្គលដែលមានសិទ្ធិកាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែល មានសិទ្ធិចូលរួមក្នុងសវនាការ។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជនត្រូវចូលរួមក្នុងសវនាការ លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនេះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះមិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន។[37] បន្ថែមលើនេះ អនីតិជនដែលរងការចោទប្រកាន់ ត្រូវបានសន្មតទុកជាមុនថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។[38] ជំនួយរបស់មេធាវីត្រូវតែមានដាច់ខាតនៅក្នុងសវនាការ បើគ្មានការជ្រើសរើសដោយអនីតិជន មេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃតាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពី លក្ខន្តិកៈមេធាវី។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿងទៅឱ្យមេធាវីសម្រាប់រៀបចំការពារ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន។

## កថាខណ្ឌទី២ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

### ២.១. សិទ្ធិប្តឹងជំទាស់ចៅក្រម

ការប្តឹងជំទាស់ចៅក្រមអាសនៈ គឺជានីតិវិធីមួយដែលអនុញ្ញាតឱ្យភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ អាចធ្វើការស្នើសុំឱ្យចៅក្រមអាសនៈដកខ្លួនចេញពីសំណុំរឿងដែលខ្លួនកំពុងកាន់ ក្នុងករណីដែលរកឃើញថាចៅក្រមអាសនៈនោះមានជាប់ពាក់ព័ន្ធនឹងទំនាក់ទំនងជាមួយភាគីនៃរឿងក្តី។ ចៅក្រមអាសនៈ សំដៅទៅលើ ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។ ទំនាក់ទំនងនេះ អាចនឹងនាំឱ្យប៉ះពាល់លើទំនុកចិត្តរបស់ភាគីចំពោះចៅក្រមអំពីការសម្រេចសេចក្តីដែលអាចជះឥទ្ធិពលដល់ការស្វែងរកយុត្តិធម៌ជូនភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ។ ចំពោះការប្តឹងជំទាស់ចៅក្រម យើងខ្ញុំនឹងធ្វើការបកស្រាយទៅលើ (ក).មូលហេតុនៃការប្តឹងជំទាស់, (ខ).លក្ខខណ្ឌនៃការប្តឹងជំទាស់ និង (គ).នីតិវិធីនៃការប្តឹងជំទាស់។

#### ក. មូលហេតុនៃការប្តឹងជំទាស់ចៅក្រមអាសនៈ

ការប្តឹងជំទាស់អាចត្រូវទទួលបានពាក់ព័ន្ធពាក់ព័ន្ធតែចៅក្រមអាសនៈប៉ុណ្ណោះ។ ក្នុងរឿងក្តីព្រហ្មទណ្ឌ ភាគីអាចធ្វើការប្តឹងជំទាស់ចៅក្រម ដោយរួមទាំងនៅក្នុងដំណាក់កាលស៊ើបសួរ និងចៅក្រមក្នុងដំណាក់កាលជំនុំជម្រះ កាលបើមានមូលហេតុដូចខាងក្រោមនេះ ៖

- កាលណាចៅក្រម ឬសហព័ទ្ធរបស់ចៅក្រម ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីណាមួយក្នុងរឿងក្តី

[37] មាត្រា ៤៧ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[38] មាត្រា ៥ នៃច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- កាលណាចៅក្រមជាញាតិលោហិតរហូតដល់ថ្នាក់ទី ៦ ឬញាតិពន្ធរហូតដល់ថ្នាក់ទី ៣ ឬអតីតញាតិពន្ធរហូតដល់ថ្នាក់ទី ៣ របស់ភាគីណាមួយ
- កាលណាចៅក្រមជាអ្នកអាណាព្យាបាលរបស់ភាគីណាមួយ
- កាលណាចៅក្រមដែលទទួលបន្ទុករឿងក្ដី ធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយភាគីណាមួយ
- កាលណាចៅក្រមបានធ្វើជាសាក្សី ឬអ្នកជំនាញក្នុងរឿងក្ដី
- កាលណាចៅក្រមជា ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឱ្យភាគីចំពោះរឿង ក្ដីឬ
- កាលណាចៅក្រមបានចូលរួមក្នុងការសម្រេចសេចក្ដីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្ដី ឬបានចូលរួមក្នុងការសម្រេចសេចក្ដីនៅសាលាដំបូងដែលបានប្ដឹងឧបាស្រ័យ ឬការជំនុំជម្រះនៃបណ្ដឹងឧទ្ធរណ៍ ដែលបានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ ចំពោះរឿងក្ដី។[39]

### ខ. លក្ខខណ្ឌនៃការប្ដឹងជិតចិត្ត

ការប្ដឹងជិតចិត្តចៅក្រមបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវស្របតាមច្បាប់ដែលបានកំណត់ ហើយក៏ត្រូវមាននូវលក្ខខណ្ឌមួយចំនួនផងដែរ។ លក្ខខណ្ឌទាំងនោះ រួមមាន ៖

- ត្រូវធ្វើបណ្ដឹងជិតចិត្តតាំងពីពេល ដែលបានដឹងពីមូលហេតុនៃការប្ដឹងជិតចិត្ត[40] មានន័យថានៅពេលភាគីនៃរឿងក្ដី បានដឹងពីមូលហេតុនៃការប្ដឹងជិតចិត្ត នោះភាគីត្រូវតែប្ដឹងជិតចិត្ត ដោយហេតុថាដំណើរការរឿងក្ដីព្រហ្មទណ្ឌគឺបន្តរហូត ដូចនេះកាលណាទុកពេលយូរ ឬអូសបន្លាយពេលវេលា នោះអាចនឹងបណ្ដាលឱ្យនីតិវិធីនៃរឿងក្ដីត្រូវបញ្ចប់ហើយការធ្វើប្ដឹងជិតចិត្ត និងពុំមានប្រយោជន៍សម្រាប់ភាគី។
- ត្រូវធ្វើនៅមុនពេលបិទការពិភាក្សាដេញដោល[41] មានន័យថាភាគីនៃរឿងក្ដី ត្រូវធ្វើការប្ដឹងជិតចិត្តនៅមុនពេលដែលបិទដំណើរការពិភាក្សាដេញដោល ហើយបើកាលណាក្រោយពេលបិទពិភាក្សាដេញដោលបានកន្លងហួស នោះភាគីមិនអាចប្ដឹងជិតចិត្តបានឡើយ។
- ពាក្យប្ដឹងជិតចិត្តត្រូវតែមានបញ្ជាក់មូលហេតុ និងភស្តុតាងច្បាស់លាស់[42]៖ ដោយមូលហេតុនៅមាត្រា ៥៥៨ កថាខណ្ឌទី២ បានចែងថាពាក្យប្ដឹងត្រូវចង្អុលបង្ហាញឱ្យច្បាស់លាស់អំពីមូលហេតុនៃការប្ដឹងជិតចិត្ត ហើយត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់ បើពុំដូច្នោះទេពាក្យប្ដឹងពុំអាចទទួលយកបានឡើង មានន័យថា ពាក្យប្ដឹងជិតចិត្តត្រូវតែមានបញ្ជាក់មូលហេតុ និងភស្តុតាងច្បាស់លាស់។

[39] មាត្រា ៥៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[40] មាត្រា ៥៥៧ កថាខណ្ឌទី១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[41] មាត្រា ៥៥៧ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[42] មាត្រា ៥៥៨ កថាខណ្ឌទី២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### គ. នីតិវិធីនៃការប្ដឹងជិតចិត្ត

ជាដំបូងពាក្យប្ដឹងជិតចិត្ត ត្រូវធ្វើឡើងដោយភាគីដែលមានសិទ្ធិ ហើយត្រូវដាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចទទួលពាក្យប្ដឹងជិតចិត្ត ដែលរួមមានប្រធានសាលាឧទ្ធរណ៍ ឬប្រធានតុលាការកំពូល។ ពាក្យប្ដឹងជិតចិត្តត្រូវសរសេរជាលាយលក្ខណ៍អក្សរ ដោយមានបញ្ជាក់នូវមូលហេតុនៃការប្ដឹងជិតចិត្ត និងបញ្ជាក់ភស្តុតាងច្បាស់លាស់។ ការជូនដំណឹងត្រូវធ្វើឡើងប្រធានសាលាឧទ្ធរណ៍ ឬ ប្រធានតុលាការកំពូល ទៅកាន់ចៅក្រមដែលត្រូវបានប្ដឹងជិតចិត្តបន្ទាប់ពីទទួលបានពាក្យប្ដឹង។[43] ក្នុងករណីនេះចៅក្រម ដែលត្រូវបានប្ដឹងជិតចិត្តត្រូវដកខ្លួនចេញក្នុងការស៊ើបសួរ ឬជំនុំជម្រះ។ ការដកខ្លួននេះមានន័យថាជាការដកខ្លួនបណ្ដោះអាសន្ន ព្រោះមិនទាន់មានសេចក្ដីសម្រេចនៅឡើយទេ ហើយក៏មិនទាន់ជំនួសដោយចៅក្រមផ្សេងដែរលើកលែងករណីបន្ទាន់។[44]

ក្នុងរយៈពេល ៨ ថ្ងៃបន្ទាប់ពីការជូនដំណឹងនេះ ចៅក្រមពាក់ព័ន្ធត្រូវប្រាប់ឱ្យដឹងនៅក្នុងរបាយការណ៍របស់ខ្លួនដោយមានសំអាងហេតុថា ខ្លួនយល់ព្រម ឬជំទាស់នឹងការប្ដឹងជិតចិត្តនេះ។ របាយការណ៍នេះ ត្រូវបញ្ជូនទៅប្រធានសាលាឧទ្ធរណ៍ ឬប្រធានតុលាការកំពូលយោងទៅតាមករណីដើម្បីសម្រេចលើពាក្យប្ដឹងជិតចិត្ត។ ប្រសិនបើចៅក្រមនេះយល់ព្រមតាមការជិតចិត្ត សាមីខ្លួនត្រូវបានចៅក្រមផ្សេងជំនួសភ្លាម។ ប៉ុន្តែប្រសិនបើចៅក្រមនេះ ជំទាស់នឹងការជិតចិត្ត នោះត្រូវធ្វើការសម្រេចលើមូលកភាពនៃពាក្យប្ដឹងនេះ។[45] បន្ទាប់ពីទទួលបានរបាយការណ៍ពីចៅក្រមពាក់ព័ន្ធនឹងពាក្យប្ដឹងជិតចិត្ត ប្រធានសាលាឧទ្ធរណ៍ ឬប្រធានតុលាការកំពូល នឹងធ្វើការពិនិត្យលើពាក្យប្ដឹង និងរបាយការណ៍ដោយមិនចាំបាច់ស្ដាប់ភាគី ឬចៅក្រមពាក់ព័ន្ធនោះទេ។[46] បន្ទាប់ពីពិនិត្យរួចហើយ សេចក្ដីសម្រេចនឹងចេញតាមរយៈដីកាសម្រេចដែលមិនអាចប្ដឹងតវ៉ាបាន។[47] បើដីកាសម្រេចទទួលយកបណ្ដឹងជិតចិត្ត ត្រូវធ្វើការចាត់តាំងចៅក្រមថ្មីជំនួសចៅក្រមដែលពាក់ព័ន្ធ ប៉ុន្តែប្រសិនបើសម្រេចថាមិនទទួលយកនោះ អ្នកប្ដឹងជិតចិត្តអាចត្រូវទទួលពិន័យមិនលើសពី ២០០.០០០ (ពីរសែន)រៀល ដោយមិនទាន់គិតដល់សំណងជំងឺចិត្ត ដែលអាចត្រូវផ្ដល់ឱ្យចៅក្រមដែលត្រូវគេប្ដឹងជិតចិត្តនោះទេ។[48]

### ២.២. សិទ្ធិត្រៀមខ្លួនគ្រប់គ្រាន់

គោលការណ៍សមភាពនៃការតទល់គ្នាតាមផ្លូវតុលាការ ទាមទារឱ្យគូភាគីចូលរួមក្នុងនីតិវិធី ដើម្បីមានពេល និងធនធានគ្រប់គ្រាន់ ដើម្បីត្រៀមការពាររឿងក្ដីរបស់ខ្លួន។ នេះជាធាតុផ្សំដ៏សំខាន់ ដើម្បីការពារឱ្យមានការជំនុំជម្រះដោយ

[43] មាត្រា ៥៥៨ កថាខណ្ឌទី១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[44] មាត្រា ៥៥៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[45] មាត្រា ៥៦០ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[46] មាត្រា ៥៦១ កថាខណ្ឌទី១ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[47] មាត្រា ៥៦២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[48] មាត្រា ៥៦១ កថាខណ្ឌទី២, ៣ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

យុត្តិធម៌ និងការអនុវត្តសិទ្ធិផ្សេងទៀត។ សិទ្ធិទទួលបានពេលវេលា និងធនធានគ្រប់គ្រាន់ពាក់ព័ន្ធនឹងសិទ្ធិរបស់ជនជាប់ចោទ «ក្នុងការទទួលបានព័ត៌មានលម្អិតភ្លាមៗ និងទទួលបានព័ត៌មានក្នុងភាសាដែលជនជាប់ចោទយល់ពីមូលហេតុនៃការចោទប្រកាន់»។ ដូច្នេះបើជនជាប់ចោទដឹងពីការចោទប្រកាន់មកលើខ្លួន កាន់តែឆាប់ ជនជាប់ចោទនឹងមានពេលវេលាកាន់តែច្រើន ក្នុងការត្រៀមការពារខ្លួន។ សិទ្ធិនេះ ក៏ទាមទារឱ្យអាជ្ញាធរមានសមត្ថកិច្ចដែលធ្វើការពាក់ព័ន្ធការបទល្មើសព្រហ្មទណ្ឌ ធ្វើសេចក្តីជូនដំណឹងផ្លូវការពីបទចោទ ឬឈ្មោះរបស់ជនជាប់ចោទ ឬជនសង្ស័យឲ្យបានលឿនតាមតែអាចធ្វើទៅបាន។

ចំពោះសិទ្ធិទទួលបានធនធានគ្រប់គ្រាន់ ជនជាប់ចោទមានសិទ្ធិទទួលបានឯកសារ និងភស្តុតាង និងជំនួយផ្នែកច្បាប់ ដើម្បីឱ្យពួកគេអាចត្រៀមការពារខ្លួននៅក្នុងរឿងក្តី។ លើសពីនេះទៅទៀត ឯកសារ និងភស្តុតាងទាំងអស់ មិនថាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក នោះទេ ត្រូវតែបង្ហាញឱ្យគ្រប់ភាគីបានឃើញ ជាពិសេសគឺជនជាប់ចោទ។ ទាំងនេះរួមមាន ភស្តុតាងដែលមានផលប្រយោជន៍ដល់ជនជាប់ចោទ និងភស្តុតាងដែលទទួលបានតាមរយៈ ការធ្វើទារុណកម្ម ឬការសារភាពដោយបង្ខំ។

សិទ្ធិក្នុងការត្រៀមការពារគ្រប់គ្រាន់ ក៏ទាមទារឱ្យជនជាប់ចោទទទួលបានជំនួយផ្នែកច្បាប់ ដែលអនុលោមនៅក្នុងគ្រប់នីតិវិធីព្រហ្មទណ្ឌទាំងអស់។ មាត្រា ១៤ (៣),(ឃ) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានចែងថា ជនជាប់ចោទអាចរើសយកការការពារខ្លួន ឬមានការតំណាងដើម្បីការពារខ្លួន។ សិទ្ធិនេះក៏ទាមទារឱ្យជនជាប់ចោទជួបជាមួយនឹងមេធាវី របស់ខ្លួនភ្លាមៗ ហើយទំនាក់ទំនងជាឯកជនរវាងជនជាប់ចោទ និងមេធាវីត្រូវបានរក្សាការសម្ងាត់។

នៅក្នុងកម្ពុជា សាលាឧទ្ធរណ៍ទំនងដូចជាមានការអនុវត្តល្អ ដោយគោរពដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការយល់ដឹងពីមូលហេតុនៃបទចោទ។ នៅក្នុងរឿងក្តីភាគច្រើន ជនជាប់ចោទ ដែលបានចូលរួមនៅក្នុងការជំនុំជម្រះទទួលបានព័ត៌មានម្តងទៀតពីបទចោទ អង្គហេតុ កាលបរិច្ឆេទ និងព័ត៌មានផ្សេងទៀតទាក់ទងនឹងការចោទប្រកាន់។

# ជំពូកទី៣

# ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

# ជំពូកទី៣

# ការដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ

## ផ្នែកទី១ ការដោះលែងឱ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដោះលែងជនត្រូវចោទ ឱ្យនៅក្រៅឃុំវិញបានគ្រប់ពេលវេលា។ ការដោះលែងក៏អាចធ្វើឡើងដោយចៅក្រមស៊ើបសួរ តាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញា និងតាមបណ្តឹងសុំរបស់ជនត្រូវចោទបានដែរ។

### កថាខណ្ឌទី១ ការដោះលែងឱ្យនៅក្រៅឃុំដោយចៅក្រមស៊ើបសួរ

#### ១.១. ក្នុងករណីធម្មតា

យោងតាមមាត្រា ២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញបានគ្រប់ពេល។ កាលណាចៅក្រមស៊ើបសួរយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នលែងចាំបាច់ដូចមានចែងក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) លែងមានការចាំបាច់ ឬចៅក្រមមានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ដោយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត (មិនត្រូវលើសពី៥ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿងមកពិនិត្យ)។ ចៅក្រមស៊ើបសួរ សម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។

#### ១.២. ក្នុងករណីបន្ទាន់

ក្នុងករណីពិសេស ដែលមានភាពបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញានោះឡើយ តែចៅក្រមស៊ើបសួរត្រូវចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃភាពបន្ទាន់ នោះនៅក្នុងដីកាសម្រេចរបស់ខ្លួន។ គួរកត់សម្គាល់ថា ក្រៅពីករណីបន្ទាន់នេះ ដីកាបង្គាប់ឱ្យដោះលែងនៅក្រៅឃុំត្រូវមានអានុភាពអនុវត្តដូចមានចែងនៅក្នុងមាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានន័យថា ជនត្រូវចោទត្រូវបានរក្សាទុកនៅក្នុងពន្ធនាគាររហូតដល់ផុតរយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម តាមសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ ដែលត្រូវដាក់បញ្ចូលក្នុងសំណុំរឿងនៃនីតិវិធី។ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអំពីដីកាដោះលែងឱ្យនៅក្រៅឃុំ ជនត្រូវចោទដែលជាប់ឃុំ ត្រូវបានរក្សាក្នុងពន្ធនាគាររហូតទាល់តែសភាស៊ើបសួរបានសម្រេចអំពីបណ្តឹងឧទ្ធរណ៍។

### កថាខណ្ឌទី២ ការដោះលែងឱ្យនៅក្រៅឃុំ តាមបណ្តឹងសុំ

#### ២.១. តាមបណ្តឹងរបស់ព្រះរាជអាជ្ញា

ទោះបីនៅក្នុងដំណាក់កាលស៊ើបសួរក៏ដោយ ក៏ព្រះរាជអាជ្ញាអាចមានវត្តមានក្នុងការសួរចម្លើយជនត្រូវចោទក្នុងការសួរតទល់ និងការស្តាប់ចម្លើយបានដែរ។ មិនត្រឹមតែប៉ុណ្ណោះព្រះរាជអាជ្ញាអាចសុំឱ្យជនត្រូវចោទនៅក្រៅឃុំបានគ្រប់ពេលគ្រប់វេលា ទៅចៅក្រមស៊ើបសួរដែលត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ។ ដីកាសម្រេចមិនព្រមដោះលែងត្រូវមានសំអាងហេតុ។

### ២.២. តាមបណ្តឹងរបស់ជនត្រូវចោទ

ជនត្រូវចោទ អាចដាក់ពាក្យសុំទៅចៅក្រមស៊ើបសួរ ឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរបញ្ជូនពាក្យនេះ និងសំណុំរឿងភ្លាមទៅព្រះរាជអាជ្ញាពិនិត្យ ដើម្បីផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុត ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប្រសិនបើជារយៈពេល ៥ (ប្រាំ) ថ្ងៃ នេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ឬបដិសេធពាក្យសុំ ជនត្រូវចោទអាចដាក់ពាក្យសុំនៅក្រៅឃុំសាជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ១ (មួយ) ខែ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធលើកមុន។ ចៅក្រមស៊ើសួរ ឬសភាស៊ើបសួរត្រូវតែសម្រេចលើពាក្យសុំខាងលើនេះក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីបានទទួលបានពាក្យសុំ។ ក្នុងករណីកន្លងផុតទៅ ៥ (ប្រាំ) ថ្ងៃ ចៅក្រមស៊ើបសួរ មិនបានសម្រេចនោះទេ ជនត្រូវចោទអាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលត្រូវសម្រេចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ជំនួសចៅក្រមស៊ើបសួរ។

នៅក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ដីកាសម្រេចនេះ ត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងប្រធានពន្ធនាគារ។[49] ប៉ុន្តែជាគោលការណ៍សេចក្តីសម្រេចឱ្យនៅក្រៅឃុំ មិនអាចយកទៅអនុវត្តបានភ្លាមទេ គឺត្រូវទុកឱ្យផុតរយៈពេលប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាសិន លើកលែងតែព្រះរាជអាជ្ញាយល់ព្រមឱ្យដោះលែងជនត្រូវចោទនោះភ្លាម ដោយសេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់ព្រះរាជអាជ្ញា ត្រូវដាក់បញ្ចូនក្នុងសំណុំរឿងនៃនីតិវិធី។ កាលណាចៅក្រមស៊ើបសួរសម្រេចឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំ ចៅក្រមនេះអាចដាក់ជននោះ ឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការវិញ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២២៣ ដល់មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**កំណត់សម្គាល់៖** ជាគោលការណ៍ច្បាប់មិនបានចែងអំពីការធានាឱ្យនៅក្រៅឃុំទេ។ ក៏ប៉ុន្តែមានមូលហេតុដែលចែងក្នុងមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន)។

***ឧទាហរណ៍:*** ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងគោលបំណង ដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។ ដូច្នេះ ប្រសិនបើជននោះមានមូលដ្ឋានធានាច្បាស់លាស់ថា មិនរត់គេចខ្លួនទេ ចៅក្រមស៊ើបសួរអាចឱ្យនៅក្រៅឃុំបាន ដោយមូលដ្ឋានធានានេះចៅក្រមស៊ើបសួរជាអ្នកសម្រេច។

---

[49] មាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

## ផ្នែកទី២ ការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្នុងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេច ដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ។ ការសម្រេចដោះលែងជនត្រូវចោទនៅក្រៅឃុំ អាចធ្វើឡើងតាម៖

- ការសម្រេចចិត្តដោយខ្លួនឯង តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- បណ្តឹងសុំដោយព្រះរាជអាជ្ញា តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ
- ពាក្យសុំរបស់ជនត្រូវចោទ តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាភ្លាម និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។[50] កាលណាចៅក្រមស៊ើបសួរ សម្រេចឱ្យដោះលែងជនត្រូវចោទនៅក្រៅឃុំ ចៅក្រមស៊ើបសួរ អាចសម្រេចដាក់ជននោះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២២៣ ដល់មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### កថាខណ្ឌទី១ ការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានឱ្យនិយមន័យនៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ ប៉ុន្តែយើងអាច កំណត់បានថា វាជាវិធានការនិរន្តរាយមួយ ដូចករណីនៃការឃុំខ្លួនបណ្តោះអាសន្នដែរ គ្រាន់តែវាជាវិធានមួយដែលមានស្ថានភាពស្រាលជាង។ ចៅក្រមស៊ើបសួរ បង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឱ្យគោរពនូវកាតព្វកិច្ចមួយ ឬច្រើន ដូចបានកំណត់ក្នុងបទបញ្ញត្តិមាត្រា ២២៣ នៃក្រមនីតីវិធីព្រហ្មទណ្ឌ។

យោងតាមការពិនិត្យលើខ្លឹមសារនៃមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏អាចឱ្យយើងកំណត់បានថា ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាវិធានមួយដែលមានកម្មវត្ថុដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការរឹតបន្តឹងខាងសេរីភាពមួយចំនួនតាមរយៈកាតព្វកិច្ច ឬការហាមឃាត់ដែលកំណត់ដោយច្បាប់។

#### ១.១. លក្ខខណ្ឌនៃការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរ អាចប្រើវិធានការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន លុះត្រាតែជនត្រូវចោទមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ និងបទល្មើសដែលត្រូវបានចោទប្រកាន់នោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ស្របនឹងខ្លឹមសារនេះ យើងអាចកំណត់បានថា ជនសង្ស័យដែលជាប់ពាក់ព័ន្ធនឹងបទល្មើសដែលមានទណ្ឌកម្មពិន័យជាប្រាក់ មិនអាចដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានឡើយ។

យោងតាមាត្រា ៤៤, ៤៥ និងមាត្រា ១២២ ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។ រីឯបទមជ្ឈិម ការស៊ើបសួរអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។ តាមខ្លឹមសារនៃមាត្រាទាំងបីនេះបញ្ជាក់ថាឱ្យឃើញថាបទលហុពុំត្រូវបានអនុញ្ញាត ឱ្យបើកការស៊ើបសួរនោះទេ។ ផ្ទុយទៅវិញមាត្រា៤៩បានកំណត់ថា ប្រសិនបើរឿងនោះជាបទលហុ

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២១៨ កឋាខណ្ឌទី១

ព្រះរាជអាជ្ញាត្រូវកោះហៅជនជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទាល់ ដូចបានចែងក្នុងមាត្រា ៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហេតុដូចនេះ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការមិនអាចអនុវត្តបានចំពោះបទលហុនោះទេ ដោយហេតុថាវិធានការនេះត្រូវបានអនុវត្តតែក្នុងយុត្តាធិការស៊ើបសួរតែប៉ុណ្ណោះ ចំណែកឯបទលហុ ត្រូវបានអនុវត្តតាមនីតិវិធីកោះហៅបញ្ជូន ទៅយុត្តាធិការជំនុំជម្រះដោយផ្ទាល់ ដោយមិនឆ្លងកាត់យុត្តាធិការស៊ើបសួរនោះឡើយ។

### ១.២. គោលដៅនៃការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ការត្រួតពិនិត្យតាមផ្លូវតុលាការមានគោលដៅសំខាន់ៗ ៤ គឺ៖

- ដើម្បីធានាឱ្យជនត្រូវចោទមកបង្ហាញខ្លួននៅចំពោះមុខតុលាការ
- បន្ថយសេរីភាពមួយចំនួន កុំឱ្យកើតមានបទល្មើសបន្តទៀត
- ដាក់កំហិតនូវការព្យាបាលផ្នែកសង្គម ឬផ្នែកវេជ្ជសាស្ត្រ
- ដាក់ប្រាក់ធានាដើម្បីទុកសងការខូចខាតដល់ជនរងគ្រោះ។

### ១.៣. នីតិវិធីនៃការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរ អាចប្រើវិធាននេះតាមគំនិតផ្តួចផ្តើមផ្ទាល់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ កាលណា ចៅក្រមស៊ើបសួរ ទទួលបណ្តឹងសុំពីព្រះរាជអាជ្ញាឱ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយចៅក្រមស៊ើបសួរ មិនសម្រេចតាមការសុំទេ ត្រូវចេញដីកាបដិសេធក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ និងត្រូវជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើមិនសម្រេចក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃទេ ព្រះរាជអាជ្ញា អាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរដែលសម្រេចជំនួស។

## កថាខណ្ឌទី២ បុគ្គលដែលអាចកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ

### ២.១. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការផងដែរ។ សេចក្តីសម្រេចនេះ ត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

### ២.២. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលវេលាទាំងអស់ ព្រះរាជអាជ្ញាអាចសុំឱ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ហើយចៅក្រមស៊ើបសួរត្រូវតែសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ ដីកាសម្រេចនេះត្រូវជូនដំណឹងយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា។ ប្រសិនបើជារយៈពេល ៥ (ប្រាំ) ថ្ងៃនេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈ

ពាក្យសុំទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញ។ ដីកាបដិសេធការប្តឹងរបស់ព្រះរាជអាជ្ញា ត្រូវតែមានសម្អាងហេតុ។

### ២.៣. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ

ជនត្រូវចោទអាចដាក់ពាក្យសុំឱ្យលើកលែង ឬកែប្រែកាតព្វកិច្ចបានគ្រប់ពេល ដោយចៅក្រមស៊ើបសួរ ត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទនោះភ្លាម និងសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យ និងផ្តល់យោបល់។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ប្រសិនបើជារយៈពេល ៥ (ប្រាំ) ថ្ងៃនេះកន្លងផុតទៅ ចៅក្រមស៊ើបសួរមិនបានសម្រេច ជនត្រូវចោទ អាចធ្វើពាក្យប្តឹងផ្ទាល់ទៅសភាស៊ើបសួរដែលសម្រេចជំនួសចៅក្រមស៊ើបសួរ។

### ២.៤. ការគេចវេសពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ

ប្រសិនបើជនត្រូវចោទ បានគេចវេសដោយចេតនាពីកាតព្វកិច្ច នៃការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរ អាចសម្រេចឃុំខ្លួនបណ្តោះអាសន្នបាន ទោះក្នុងករណីដែល៖

- ទោសជាប់ពន្ធនាគារដែលត្រូវរងនោះ មានថិរវេលាប៉ុន្មានក៏ដោយ (មានន័យថាលក្ខខណ្ឌនៃមាត្រា ២០៤ លែងជាឧបសគ្គនៃការឃុំខ្លួនបណ្តោះអាសន្នទៀតហើយ)
- ជនត្រូវចោទត្រូវបានឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលអតិបរមានៃថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នតាមមាត្រា ២០៨,២០៩,២១០,២១៣ និង ២១៤ ក៏ដោយ។

កាលណាសម្រេចថា នឹងឃុំខ្លួនបណ្តោះអាសន្នដោយមូលហេតុខាងលើនេះ ចៅក្រមស៊ើបសួរ ត្រូវជូនដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជននេះ ហើយត្រូវឱ្យមេធាវីជូនមធ្យោបាយការពារ ប្រសិនបើមានមេធាវីអមផងនោះ។ ដីកាសម្រេច ត្រូវមានសំអាងហេតុ និងត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ការឃុំខ្លួនបណ្តោះអាសន្ន ដែលសម្រេចតាមមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ មិនអាចឱ្យលើសពី ៤ ខែ ចំពោះនីតិជន និងមិនអាចលើសពី ២ ខែ ចំពោះអនីតិជនឡើយ។

ការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវបានបញ្ចប់នៅពេលដែលចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចរក្សាទុកជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការនោះទេ។[51]ការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវបញ្ចប់នៅពេលដែលតុលាការប្រកាសសាលក្រមដែរ។[52]

[51] មាត្រា២៤៩ កថាខណ្ឌទី៤ និងទី៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[52] មាត្រា៣៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានឆ្លងកាត់នូវការសិក្សាស្រាវជ្រាវ ប្រកបដោយការយកចិត្តទុកដាក់រួចមក ក៏បានប្រមូលចងក្រងនូវប្រធានបទស្តីពី «**ការឃុំខ្លួនបណ្តោះអាសន្ន នៃដំណាក់កាលចៅក្រមស៊ើបសួរ**» បានបង្ហាញឱ្យយើងឃើញថា ដំណើរការនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលត្រូវប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវ ហ្មត់ចត់ និងត្រូវអនុលោមភាពតាមច្បាប់ជាធរមាន។

ការឃុំខ្លួនបណ្តោះអាសន្ន ជានីតិវិធីមួយដែលធ្វើឡើងនៅមុនពេលជម្រះក្តី ក្នុងពេលដែលសំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ ការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើឡើងតាមរយៈគំនិតផ្តើមពីចៅក្រមស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដោយយោងតាមការពិចារណា ការស្វែងយល់ដោយផ្ទាល់ទៅលើបុគ្គលិកលក្ខណៈរបស់ជនត្រូវចោទ ឬស្ថានភាពជាក់ស្តែងនៃបទល្មើសដែលបានប្រព្រឹត្ត។ ក្នុងករណីការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ឡើងទៅការឃុំខ្លួនបណ្តោះអាសន្ន ត្រូវតែមានលក្ខខណ្ឌ និងមូលហេតុចាំបាច់ ដែលមូលហេតុនេះ រួមមាន បញ្ចប់បទល្មើស ឬបង្ការកុំឱ្យបទល្មើសកើតមាន រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬត្រូវរ៉ូវគ្នាជាមួយអ្នកសមគំនិត រក្សាភស្តុតាង ឬតម្រុយសម្ភារៈ ធានារក្សាជនត្រូវចោទទុកជូនតុលាការ ការពារសន្តិសុខឱ្យជនត្រូវចោទ និងរក្សាសណ្តាប់ធ្នាប់សាធារណៈ។

នៅពេលដែលចៅក្រមស៊ើបសួរ សម្រេចពីការឃុំខ្លួនបណ្តោះអាសន្ន នោះគឺត្រូវធ្វើឡើងតាមរយៈ «ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន» ដែលត្រូវជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវឱ្យដំណឹងដល់ជនត្រូវចោទឱ្យបានដឹង ហើយបើជនត្រូវចោទមានមេធាវីអម មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន។ បន្ទាប់ពីចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរួចរាល់ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដែលដីកានេះគឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនជនត្រូវចោទ។

ទន្ទឹមនឹងនេះ ការឃុំខ្លួនបណ្តោះអាសន្នក៏មានចិរវេលាផងដែរ ដែលចិរវេលានេះអាស្រ័យទៅលើប្រភេទបទល្មើស អាចជាបទមជ្ឈិម ឬបទឧក្រិដ្ឋ ព្រមទាំងត្រូវធ្វើការបែងចែកជនត្រូវចោទ ជានីតិជន ឬអនីតិជន ហើយចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ននេះទៀតសោត ប្រសិនបើកាលណាផុតចិរវេលា ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួនបណ្តោះអាសន្ននេះបាន ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

បន្ថែមពីលើនេះ កាលណាចៅក្រមស៊ើបសួរ មានបំណងដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំវិញ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានដល់ព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងខ្លីបំផុត។ បន្ទាប់មក ចៅក្រមស៊ើបសួរ ត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ មួយវិញទៀត ការដោះលែងឱ្យនៅក្រៅឃុំ អាចធ្វើឡើងដោយគំនិតរបស់ចៅក្រមស៊ើបសួរ ឬតាមបណ្តឹងរបស់ព្រះរាជអាជ្ញា ឬតាមបណ្តឹងរបស់ជនត្រូវចោទ។ ដីកាសម្រេចដោះលែងឱ្យនៅ

ក្រៅឃុំ ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន។ កាលណា ចៅក្រមស៊ើបសួរ សម្រេចឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ ចៅក្រមស៊ើបសួរអាចដាក់ជននោះឱ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ប្រសិនបើ ដីកាមិនព្រមដោះលែងឱ្យនៅក្រៅឃុំ ត្រូវតែជូនដំណឹងក្នុងរយៈពេលយ៉ាងខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ដូចដែលបានអធិប្បាយ ឬលើកឡើងនៅអត្ថបទខាងលើនេះ យើងអាចសន្និដ្ឋានបានថា តួនាទីចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ គឺដើម្បីស្វែងរកភាពពិតប្រាកដ និងស្វែងរកភស្តុតាងនៃសំណុំរឿងព្រហ្មទណ្ឌ ដើម្បីឱ្យមានតម្លាភាព និងសុក្រឹត្យភាព ដោយរក្សាបាននូវស្ថិរភាពនៃនីតិវិធីក្នុងរឿងក្តី គោរពបាននូវសិទ្ធិរបស់បុគ្គលពាក់ព័ន្ធព្រមទាំងបានផ្តល់នូវ ភស្តុតាងយ៉ាងប្រត្យក្សចំពោះអង្គហេតុដែលបានកើតឡើង។ ការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺជាវិធានការនិរន្តរាយមួយក្នុងចំណោមវិធានផ្សេងៗទៀតដែលអនុញ្ញាតឱ្យ ចៅក្រមស៊ើបសួរ អាចធ្វើទៅបានក្នុងគោលបំណង ដើម្បីធានានៅកិច្ចនៃការស៊ើបសួររបស់ខ្លួនប្រព្រឹត្តទៅបានដំណើរការល្អប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងការស្វែងរកឱ្យឃើញពីអត្ថិភាពនៃអង្គហេតុឱ្យឃើញពីពិរុទ្ធភាពរបស់ជនត្រូវចោទ។ ការឃុំខ្លួនបណ្តោះអាសន្នដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ មានលក្ខណៈកាត់បន្ថយនូវសិទ្ធិសេរីភាពរបស់ជនត្រូវចោទ ប៉ុន្តែក៏អាចបកស្រាយបានថាការអនុវត្ត វិធាននេះ គឺធ្វើឡើងក្នុងគោលបំណងរក្សាសុវត្ថិភាព និងសន្តិសុខចំពោះជនត្រូវចោទ ក៏ដូចជាបង្កាការពារជនត្រូវចោទមិនឱ្យទៅបង្ក ឬប្រព្រឹត្តនៅបទល្មើសផ្សេងទៀត ដែលនាំឱ្យប៉ះពាល់បន្ថែមទៀតទៅដល់ជនដទៃផ្សេងទៀត រួមទាំងផលប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គមជាតិផងដែរ។

សរុបសេចក្តីមក ការឃុំខ្លួនបណ្តោះអាសន្ននៃដំណាក់កាលចៅក្រមស៊ើបសួរ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះបញ្ញាវន្តផ្នែកច្បាប់ រួមទាំងអ្នកអាន អ្នកសិក្សាស្រាវជ្រាវផងដែរ ដោយបានបង្ហាញនូវសញ្ញាណទូទៅនៃកិច្ចស៊ើបសួរ នីតិវិធីនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលរួមបញ្ចូលនូវមូលហេតុ ចិរវេលា ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន និងសិទ្ធិរបស់ជនត្រូវចោទ ព្រមទាំងនីតិវិធីដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំ និងការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

# អនុសាសន៍

ក្រោយពីឆ្លងកាត់នូវការស្រាវជ្រាវ និងបកស្រាយលើប្រធានបទស្តីពី ការឃុំខ្លួនបណ្តោះអាសន្ន នៃដំណាក់កាលចៅក្រមស៊ើបសួររួចមក យើងសង្កេតឃើញថា ការឃុំខ្លួនបណ្តោះអាសន្ននេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក្នុងដំណើរការនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ក៏នៅតែមានភាពចន្លោះប្រហោងដែលត្រូវមានការកែតម្រូវ និងបំពេញបន្ថែមផងដែរ។

- ការឃុំខ្លួនបណ្តោះអាសន្ន គឺជាការរារាំងនូវសិទ្ធិសេរីភាពរបស់បុគ្គលក្នុងរយៈពេលមួយដែលកំណត់ដោយច្បាប់ ហេតុនេះការឃុំខ្លួនបណ្តោះអាសន្ន នៃដំណាក់កាលចៅក្រមស៊ើបសួរ គឺចៅក្រមស៊ើបសួរត្រូវតែមានមូលហេតុជាក់លាក់ និងចាំបាច់ខ្លាំងបំផុត ទើបត្រូវឃុំខ្លួនបណ្តោះអាសន្ន។ កាលណាចៅក្រមស៊ើបសួរ ធ្វើឡើងតាមឆន្ទានុសិទ្ធិផ្ទាល់ខ្លួន ឬតាមរយៈការស្នើសុំរបស់ព្រះរាជអាជ្ញា ក្នុងការសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនណាមួយដោយគ្មានមូលហេតុជាក់លាក់ដែលមានចែងក្នុងច្បាប់ជាធរមានទេ ជាហេតុបណ្តាលឱ្យមានការរំលោភបំពានលើសិទ្ធិមនុស្សយ៉ាងខ្លាំង ដែលសិទ្ធិមនុស្សនេះត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ និងលិខិតុបករណ៍អន្តរជាតិ ហើយទន្ទឹមនឹងនេះ ក៏ជាផ្នែកមួយដែលបង្កឱ្យមានការចង្អៀតណែនក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនផងដែរ។ ប្រសិនបើ បុគ្គលដែលជាជនត្រូវចោទ មានការធានាច្បាស់លាស់ មិនគេចវេសទៅទីណា និងហ៊ានប្រឈមមុខដោះស្រាយនូវរាល់បញ្ហាទាំងអស់ចំពោះមុខច្បាប់ ហេតុនេះចៅក្រមស៊ើបសួរ ត្រូវគិតពិចារណាឱ្យបានច្បាស់លាស់ និងក្នុងស្ថានភាពបែបនេះ ចៅក្រមស៊ើបសួរ គួរតែសម្រេចដាក់ជនត្រូវចោទនោះឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីជំនួសឱ្យវិធានការនៃការឃុំខ្លួនបណ្តោះអាសន្នវិញ។

- បន្ថែមពីនេះ ចំណុចដែលខ្វះខាតនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងភាពខ្វះចន្លោះក្នុងការអនុវត្តនៅតាមសាលាដំបូង គប្បីពិចារណាវិធានអន្តរជាតិ (យោងតាមសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ កបធ.ច ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញ បានចែងថា ជាគោលការណ៍ ក្នុងការជំនុំជម្រះក្តី ចៅក្រមពុំមែនគ្រាន់តែផ្អែកទៅលើមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋតែមួយនេះទេ ដើម្បីផ្តន្ទាទោសលើឧក្រិដ្ឋជន ប៉ុន្តែចៅក្រមត្រូវផ្អែកលើច្បាប់។ ពាក្យថាច្បាប់ខាងលើនេះ មានន័យថា ច្បាប់ជាតិ រួមមានរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលច្បាប់ទាំងឡាយដែលនៅជាធរមាន ហើយនិងច្បាប់អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់រួចមកហើយជាពិសេសអនុសញ្ញាស្តីពីសិទ្ធិកុមារ)។ ចំពោះជនរងគ្រោះ ដែលធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គួរគប្បីពិនិត្យឱ្យបានច្បាស់លាស់រាល់ការដាក់ភស្តុតាង និងឯកសារដែលបង្ហាញពីព្យសនកម្មទាំងផ្លូវកាយ ផ្លូវចិត្ត និងព្យសនកម្មសម្ភារៈ។

- តួយ៉ាងក្រសួងយុត្តិធម៌ ដើរតួយ៉ាងសំខាន់ក្នុងការជួយសម្រួល និងផ្តល់ជាអនុសាសន៍ ក្នុងនាមជាអ្នកដឹកនាំ និងគ្រប់គ្រងវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទី និងភារកិច្ច ដូចមានចែងក្នុងមាត្រា ២ និងមាត្រា ៣ នៃអនុក្រឹត្យលេខ ១៣០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២ គួរផ្តល់អនុសាសន៍ឱ្យបានច្រើនពាក់ព័ន្ធនឹងការឃុំខ្លួនជាបណ្តោះអាសន្ន ទៅលើជនត្រូវចោទក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ព្រោះកន្លងមកស្ទើគ្រប់សំណុំរឿងព្រហ្មទណ្ឌ គឺសុទ្ធតែមានការឃុំខ្លួនជាបណ្តោះអាសន្ន

(ដោយយោងតាមសេចក្ដីណែនាំលេខ ០១ កយ.សណន/២០ របស់ក្រសួងយុត្តិធម៌ កថាខណ្ឌទី២ នៃចំណុចទី២) ជាហេតុធ្វើឱ្យមានការកកស្ទះសំណុំរឿង នៅដំណាក់កាលស៊ើបសួរ និងចង្អៀតណែនពន្ធនាគារជាខ្លាំង រួមទាំងធ្វើឱ្យខាតបង់ថវិកាជាតិ។ ក្នុងករណីសំណុំរឿងមួយចំនួនមានភស្តុតាងគ្រប់គ្រាន់អាចជំនុំជម្រះបាន គួរគប្បីប្រើប្រាស់វិធានការបញ្ជូនទៅជម្រះភ្លាម ដោយឡែកចំពោះបទមជ្ឈិមដែលពុំមានលក្ខណៈធ្ងន់ធ្ងរ គួរគប្បីពិចារណាលើវិធានការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជំនួសឱ្យការឃុំខ្លួនបណ្ដោះអាសន្នវិញ។

ជាកិច្ចចុងក្រោយនេះ យើងខ្ញុំសង្ឃឹមថា ការសរសេរប្រធានបទនេះ ជាប្រភពពត៌មានថ្មី និងជាដំណើរការមួយដែលជាការដាស់តឿន ដល់ស្ថាប័នអនុវត្តច្បាប់ទាំងអស់ត្រូវតែយកចិត្តទុកដាក់ និងពង្រឹងឱ្យដំណើរការអនុវត្តឱ្យបានល្អ។

# គន្ថនិទ្ទេស

## ១. លិខិតបទដ្ឋានគតិយុត្តជាតិ

### ១.១. អំពីរដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

### ១.២. អំពីក្រម

ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩

### ១.៣. អំពីច្បាប់

ច្បាប់ស្តីពី លក្ខន្តិកៈមេធាវី ឆ្នាំ១៩៩៥

ច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ឆ្នាំ២០១៤

ច្បាប់ស្តីពី លក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ឆ្នាំ២០១៤

ច្បាប់ស្តីពី យុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ១.៤. អនុក្រឹត្យ

អនុក្រឹត្យលេខ ១៣០ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២២

### ១.៥. សេចក្តីណែនាំ

សេចក្តីណែនាំ លេខ០៣.កយ.សណន/២១ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ របស់ក្រសួងយុត្តិធម៌

## ២. លិខិតបទដ្ឋានគតិយុត្តអន្តរជាតិ

សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស  ឆ្នាំ១៩៤៨

កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៧៦

អនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិកុមារ ឆ្នាំ១៩៨៩

## ៣. សៀវភៅដែលពាក់ព័ន្ធ និងឯកសារផ្សេងៗ

- សៀវភៅ នីតិវិធីនៃការបើកការស៊ើបសួររបស់អយ្យការ របស់ **លោក អៀង សំអាង** ឆ្នាំ២០២០
- សៀវភៅដំណើរការរឿងក្តីព្រហ្មទណ្ឌនៅកម្ពុជាបច្ចុប្បន្នរបស់**ឧត្តមសេនីយ៍ត្រី អាន សុវីដា**បោះពុម្ពលើកទី២
- សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅកម្ពុជា របស់ **លោក សយ គីមសាន**
- វចនានុក្រម ក្នុងកម្មវិធីតម្រាច្បាប់

# **ឧបសម្ព័ន្ធ**

## **បញ្ជីរាយនាមឧបសម្ព័ន្ធ**


| | |
|---|---|
| **ឧបសម្ព័ន្ធទី ១** | ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ |
| **ឧបសម្ព័ន្ធទី ២** | ដីកាចាត់ឱ្យស៊ើបសួរជំនួស |
| **ឧបសម្ព័ន្ធទី ៣** | ដីកាបង្គាប់ឱ្យចូលខ្លួន |
| **ឧបសម្ព័ន្ធទី ៤** | ដីកាបង្គាប់ឱ្យនាំខ្លួន |
| **ឧបសម្ព័ន្ធទី ៥** | ដីកាបង្គាប់ឱ្យចាប់ខ្លួន |
| **ឧបសម្ព័ន្ធទី ៦** | ដីកាបង្គាប់ឱ្យឃុំខ្លួន |
| **ឧបសម្ព័ន្ធទី ៧** | ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី ៨** | ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី ៩** | ដីកាបង្គាប់ឱ្យដោះលែង |
| **ឧបសម្ព័ន្ធទី ១០** | លិខិតប្រគល់សិទ្ធិតំណាង |
| **ឧបសម្ព័ន្ធទី ១១** | ពាក្យសុំពឹងពាក់មេធាវី |

ព្រះរាជាណាចក្រកម្ពុជា

**ឧបសម្ព័ន្ធទី ១**

**អយ្យការអម**

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្ត-ក្រុង

**********

.........................

***********

# ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

លេខ......................

************

យើង.......................................... តំណាងអយ្យការអមតុលាការខេត្ត-ក្រុង ...................................... ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.................... ចុះថ្ងៃទី............ ខែ ............ ឆ្នាំ ............. និងសំណុំលិខិតភ្ជាប់មកជាមួយ ព្រមទាំងភស្តុតាងនានា ។

សម្រេចផ្តើមចោទប្រកាន់ឈ្មោះ ........................................ ភេទ............ អាយុ .........ឆ្នាំ ជាតិ........... របររកស៊ី...................................... ទីលំនៅបច្ចុប្បន្ននៅភូមិ.........................ឃុំ-សង្កាត់.................................. ស្រុក-ខណ្ឌ...........................................ខេត្ត-ក្រុង.....................................ទោសពីមុន ......................... និងគូកន ។ ឪពុកឈ្មោះ........................................ "រ-ស" ម្តាយឈ្មោះ ........................................ "រ-ស" ប្តីឬប្រពន្ធឈ្មោះ................................................"រ-ស" មានកូន ឬនៅលីវ ................................ ត្រូវជាប់ចោទពីបទ...................................................................... ប្រព្រឹត្តនៅភូមិ............................................. ឃុំ-សង្កាត់........................... ស្រុក-ខណ្ឌ.............................. ខេត្ត-ក្រុង.......................................កាលពីថ្ងៃទី ......... ខែ ................. ឆ្នាំ .................... តាមមាត្រា............................................................ នៃច្បាប់ ..................................................................................................................................................... ។

.....................................................................................................................................................

.....................................................................................................................................................

..................................................................................................................................................... ។

.....................................................................................................................................................

.....................................................................................................................................................

..................................................................................................................................................... ។

.....................................................................................................................................................

.....................................................................................................................................................

បញ្ជូនសំណុំរឿង វត្ថុតាង និងជនល្មើស "មានខ្លួន, គ្មានខ្លួន" ទៅចៅក្រមស៊ើបអង្កេត នៃតុលាការខេត្ត-ក្រុង ..... ............................................................ ដើម្បីចាត់ការតាមច្បាប់ និងស្នើសុំ ............................................ ។

ធ្វើនៅ............................. ថ្ងៃទី........... ខែ................. ឆ្នាំ.............

**ព្រះរាជអាជ្ញា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

..........

**ឧបសម្ព័ន្ធទី ២**

Logo

## <u>ដីកាចាត់ឱ្យស៊ើបសួរជំនួស</u>

**សាលាដំបូង.................**

លេខ: .......................

យើង............................... ចៅក្រមស៊ើបសួរ នៃសាលាដំបូង ..........................................

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ..................... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ ........... ដែលមានវិមតិសង្ស័យលើឈ្មោះ........................... អាយុ......... ឆ្នាំ ភេទ.......... ជាតិ ......... សាសនា.................. មុខរបរ............................. ទីលំនៅបច្ចុប្បន្ននៅភូមិ ................................ ឃុំ-សង្កាត់......................... ស្រុក-ខណ្ឌ........................... ខេត្ត-ក្រុង .................... ទោសពីមុន....................................។

ឪពុកឈ្មោះ.......................... "រ-ស" ម្ដាយឈ្មោះ.............................. "រ-ស" ប្ដី ឬប្រពន្ធឈ្មោះ ............................"រ-ស" មានកូន ឬនៅលីវ............................. ត្រូវជាប់ចោទពីបទ ......................................... ប្រព្រឹត្តនៅភូមិ....................................ឃុំ-សង្កាត់...................... ស្រុក-ខណ្ឌ.............................. ខេត្ត-ក្រុង.................... កាលពីថ្ងៃទី...... ខែ........ ឆ្នាំ............ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាម មាត្រា............... នៃច្បាប់........................។

យល់ឃើញថា .......................................................................................................... .......................................................................................................................................... .........................................................................................................................................។

## <u>ហេតុដូច្នេះ សម្រេច</u>

១- ប្រគល់សិទ្ធិជូនលោក-លោកស្រី............................ ជា................................ ដើម្បីចាត់ការៈ

១- ...........................................................................................................................

២- ...........................................................................................................................

៣- ........................................................................................................................................

២- ក្រោយពីបានសួរយកចម្លើយចប់សព្វគ្រប់ហើយ ត្រូវបញ្ជូនលទ្ធផល មកយើងវិញឱ្យបានឆាប់បំផុត។

ថ្ងៃ................ ខែ........... ឆ្នាំ..... សំរិទ្ធិស័ក ព.ស ២៥៦...

ធ្វើនៅ..............., ថ្ងៃទី...... ខែ...... ឆ្នាំ២០......

**ចៅក្រមស៊ើបសួរ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

...............

Logo

**ឧបសម្ព័ន្ធទី ៣**

**សាលាដំបូង..................**

លេខ: .........................

## ដីកាបង្គាប់ឱ្យចូលខ្លួន

**(មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)**

យើង .................................................. ចៅក្រមស៊ើបសួរនៃសាលាដំបូង ...........................

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: .................. ចុះថ្ងៃទី......... ខែ....... ឆ្នាំ២០....។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូលរឿងឱ្យស៊ើបសួរលេខ ..... អ.យ.ប ចុះថ្ងៃទី..... ខែ..... ឆ្នាំ ២០...។

បើកការស៊ើបសួរលើឈ្មោះ............. ភេទ........ អាយុ ......ឆ្នាំ កើតនៅថ្ងៃទី....... ខែ........ ឆ្នាំ ១៩..... ជនជាតិ...... ពីបទ៖ ................................ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី...... ខែ....... ឆ្នាំ២០...... តាមបញ្ញត្តិមាត្រា .................. នៃក្រមព្រហ្មទណ្ឌ។

បង្គាប់មកឈ្មោះ.................... ភេទ........ អាយុ ......ឆ្នាំ កើតនៅថ្ងៃទី....... ខែ........ ឆ្នាំ១៩....... ជនជាតិ....... មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះ......... សង្កាត់......... ខណ្ឌ............. រាជធានីភ្នំពេញ (អាស័យដ្ឋានចុងក្រោយ)។

ឱ្យចូលខ្លួនមកកាន់សាលាដំបូង................. បន្ទប់ "............" ជាន់ទី............ នៅថ្ងៃទី..... ខែ .......... ឆ្នាំ២០...... វេលាម៉ោង ........ និង........ នាទីព្រឹក។

ដើម្បី ៖ មកសាកសួរយកចម្លើយ ពីដំណើររឿង៖ ............................................................................

សាមីខ្លួនត្រូវយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផង ប្រសិនបើមាន។

ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើនេះទេ យើងនឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន។

ថ្ងៃ............ ខែ............ ឆ្នាំ..... សំរិទ្ធិស័ក ព.ស ២៥៦...

ធ្វើនៅ............. ថ្ងៃទី...... ខែ...... ឆ្នាំ២០......

**យល់ឃើញថា:** ដើម្បីជានាការស៊ើបសួរឱ្យបានពេញលេញ គប្បីសម្រេចនាំខ្លួន ឈ្មោះ ............ ភេទ..... កើតថ្ងៃទី...... ខែ....... ឆ្នាំ១៩.... មកចំពោះមុខចៅក្រមស៊ើបសួរដើម្បីសួរបំភ្លឺការពិតក្នុងសំណុំរឿងខាងលើ។

**<u>ហេតុដូច្នេះសម្រេច</u>**

១. ឱ្យនាំខ្លួនឈ្មោះ ................ ភេទ.... កើតថ្ងៃទី..... ខែ...... ឆ្នាំ១៩..... កាន់អត្តសញ្ញាណប័ណ្ណលេខ .......... ចុះថ្ងៃទី..... ខែ....... ឆ្នាំ២០..... ជនជាតិ..... មុខរបរ.............. ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ...... ផ្លូវ.... ក្រុមទី..... ភូមិ...... សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ ដើម្បីសាកសសួរយកព័ត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងខាងលើ ត្រឹមថ្ងៃទី..... ខែ....... ឆ្នាំ២០..... ជាកំណត់។

២. បង្គាប់ទៅភ្នាក់ងារមានសមត្ថកិច្ច ឱ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធីច្បាប់។

ថ្ងៃ............ ខែ............ ឆ្នាំ..... សំរិទ្ធិស័ក ព.ស ២៥៦...

ធ្វើនៅ ............, ថ្ងៃទី...... ខែ...... ឆ្នាំ២០......

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី ៤**

Logo

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

............

**សាលាដំបូង..................**

លេខ: .........................

**<u>ដីកាបង្គាប់ឱ្យនាំខ្លួន</u>**

យើង ......................... ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា ១៨៩ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ........... ចុះថ្ងៃទី..... ខែ....... ឆ្នាំ២០......។
- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ...... អ.យ.ជ ចុះថ្ងៃទី... ខែ... ឆ្នាំ...... របស់អយ្យការអមសាលាដំបូង...................។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ .......... ចុះថ្ងៃទី....... ខែ......... ឆ្នាំ២០......

**យល់ឃើញថា:** ឈ្មោះ .......... ភេទ......... កើតថ្ងៃទី..... ខែ........ ឆ្នាំ១៩..... កាន់អត្តសញ្ញាណប័ណ្ណលេខ ................ ចុះថ្ងៃទី...... ខែ...... ឆ្នាំ២០..... ជនជាតិ....... មុខរបរ............ មានទីកន្លែងកំណើតនៅ សង្កាត់............ ខណ្ឌ........... រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ.......... ផ្លូវ......... ក្រុមទី......... ភូមិ........... សង្កាត់............ ខណ្ឌ........... រាជធានីភ្នំពេញ ឪពុកឈ្មោះ .......... ម្តាយឈ្មោះ ............. ។

ជននេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ .................. ប្រព្រឹត្តនៅចំណុច ........ ផ្លូវលេខ........ ភូមិ........... សង្កាត់.......... ខណ្ឌ.......... រាជធានីភ្នំពេញ កាលពីថ្ងៃទី...... ខែ ........ ឆ្នាំ២០........ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា...... និង មាត្រា ........ នៃក្រមព្រហ្មទណ្ឌ។

**យល់ឃើញថា៖** ក្រោយពេលប្រព្រឹត្តបទល្មើសរួចជនត្រូវចោទបានលួចរត់គេចខ្លួន។

**យល់ឃើញថា:** ដើម្បីជានាការស៊ើបសួរឱ្យបានពេញលេញ គប្បីសម្រេចនាំខ្លួន ឈ្មោះ ............ ភេទ..... កើតថ្ងៃទី...... ខែ....... ឆ្នាំ១៩.... មកចំពោះមុខចៅក្រមស៊ើបសួរដើម្បីសួរបំភ្លឺការពិតក្នុងសំណុំរឿងខាងលើ។

**<u>ហេតុដូច្នេះសម្រេច</u>**

១. ឱ្យនាំខ្លួនឈ្មោះ ................ ភេទ.... កើតថ្ងៃទី..... ខែ...... ឆ្នាំ១៩..... កាន់អត្តសញ្ញាណប័ណ្ណលេខ .......... ចុះថ្ងៃទី..... ខែ....... ឆ្នាំ២០..... ជនជាតិ..... មុខរបរ.............. ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ...... ផ្លូវ.... ក្រុមទី..... ភូមិ...... សង្កាត់.......... ខណ្ឌ......... រាជធានីភ្នំពេញ ដើម្បីសាកសួរយកព័ត៌មានផ្សេងៗ ទាក់ទងនឹងសំណុំរឿងខាងលើ ត្រឹមថ្ងៃទី..... ខែ....... ឆ្នាំ២០..... ជាកំណត់។

២. បង្គាប់ទៅភ្នាក់ងារមានសមត្ថកិច្ច ឱ្យចាប់ និងនាំខ្លួនឈ្មោះខាងលើនេះមកប្រគល់ជូនសាលាដំបូងរាជធានីភ្នំពេញ ចាត់ការតាមនីតិវិធីច្បាប់។

ថ្ងៃ............ ខែ............ ឆ្នាំ..... សំរិទ្ធិស័ក ព.ស ២៥៦...

ធ្វើនៅ ............, ថ្ងៃទី...... ខែ...... ឆ្នាំ២០......

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី ៥**

**ព្រះរាជាណាចក្រកម្ពុជា**

Logo

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**សាលាដំបូង.................**

**ដីកាបង្គាប់ឱ្យចាប់ខ្លួន**

លេខ: ........................

យើង ..........................................។........ ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា ១៩៥ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ......... ចុះថ្ងៃទី..... ខែ..... ឆ្នាំ២០......។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី..... ខែ.... ឆ្នាំ២០....។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ...... ចុះថ្ងៃទី.... ខែ..... ឆ្នាំ២០....។
- បានឃើញ ដីកាបញ្ជូនឱ្យឆ្លើយលេខ ........ ម.ព្រ.ទ ចុះថ្ងៃទី..... ខែ...... ឆ្នាំ២០..... របស់ចៅក្រមស៊ើបសួរនៃសាលាដំបូង............... និងយោបល់របស់ព្រះរាជអាជ្ញា។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ យល់ឃើញថា:**

ឈ្មោះ .................... ភេទ....... អាយុ.....ឆ្នាំ ជន....... សញ្ជាតិ....... ទីកន្លែងកំណើត........ ឃុំ........... ស្រុក................. ខេត្ត........... ទីលំនៅបច្ចុប្បន្នផ្ទះលេខ........ ផ្លូវលេខ........ ភូមិ ............ សង្កាត់............... ខណ្ឌ............ រាជធានីភ្នំពេញ ជា.......... (គេចខ្លួន)។

ត្រូវចោទប្រកាន់ពីបទ ................. ប្រព្រឹត្តនៅប្រទេសកម្ពុជា និងទីកន្លែងផ្សេងទៀត កាលពីថ្ងៃទី............... តាមបញ្ញត្តិមាត្រា ......... និងមាត្រា ......... នៃក្រមព្រហ្មទណ្ឌ។

ឃើញថា តាមរបាយការណ៍លេខ ......... របក.នបកក ចុះថ្ងៃទី..... ខែ...... ឆ្នាំ២០..... របស់នាយកដ្ឋាន......... បានបញ្ជាក់ថា ឈ្មោះខាងលើពុំមានវត្តមាននៅតាមទីលំនៅក្នុងមូលដ្ឋានរបស់ខ្លួនក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូច្នេះតុលាការគប្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនត្រូវចោទឈ្មោះ ............... ភេទ..... អាយុ.....ឆ្នាំ ជនជាតិ..... សញ្ជាតិ..... ដើម្បីអោយជនត្រូវចោទមកបង្ហាញខ្លួនចំពោះមុខតុលាការដើម្បីរកការពិតក្នុងរឿងក្តីនេះ។

**ហេតុដូច្នេះសម្រេច**

១. បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ .................. ដែលមានអត្តសញ្ញាណខាងលើនេះ។

២. បញ្ជាដល់កងកម្លាំងសាធារណៈ ឱ្យស្រាវជ្រាវរកចាប់ និងនាំខ្លួនឈ្មោះខាងលើនេះ មក ប្រគល់ជូន សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។

ថ្ងៃ.................. ខែ........ ឆ្នាំ....... សំរឹទ្ធិស័ក ព.ស ២៥៦....

ធ្វើនៅ..............., ថ្ងៃទី.... ខែ..... ឆ្នាំ២០២....

**ចៅក្រមស៊ើបសួរ**

Logo

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

**ឧបសម្ព័ន្ធទី ៦**

សាលាដំបូងខេត-រាជធានី

មន្ទីរស៊ើបសួរ បន្ទប់ (......)

លេខ...............................

<u>**ដីកាបង្គាប់ឱ្យឃុំខ្លួន**</u>

យើង ......................... ចៅក្រមស៊ើបសួរ សាលាដំបូង.............................

- បានឃើញ មាត្រា២០៦ មាត្រា២១៩ មាត្រា២២០ មាត្រា២២១ និងមាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ............... ចុះថ្ងៃទី..... ខែ......... ឆ្នាំ.........។

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ............ ចុះថ្ងៃទី..... ខែ....... ឆ្នាំ...... ។

- បានឃើញសំណុំរឿងស៊ើបសួរលេខលេខ................ ចុះថ្ងៃទី..... ខែ....... ឆ្នាំ.......... ទាក់ទងទៅនឹង៖

នាមត្រកូល និងនាមខ្លួន ................... ភេទ....... អាយុ.........ជនជាតិ......... មុខរបរ .......... ទីកន្លែងកំណើត ភូមិ.....................ឃុំ/សង្កាត់..................... ស្រុក/ខណ្ឌ/ក្រុង................. ខេត្ត/រាជធានី................. មានទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះលេខ........ ផ្លូវលេខ......... ភូមិ ..................... ឃុំ/សង្កាត់.............. ស្រុក/ខណ្ឌ/ក្រុង............... ខេត្ត/រាជធានី........................ ឪពុ□ឈ្មោះ....□.. រស់ ស្លាប់ ម្តាយ□ោះ......□...... រស់ ស្លាប់ ប្តី/ប្រ□ឈ្មោះ □ .............រស់ ស្លាប់ □នកូន.....□ក់ ឬនៅលី□ នីតិជន អនីតិជន ។

ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ មាន □ គ្មាន □។

ជននេះ ត្រូវដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទ ................................ ប្រព្រឹត្តនៅចំនុចមុខផ្ទះលេខ......... ផ្លូវលេខ......... ភូមិ...................ឃុំ/សង្កាត់................. ស្រុក/ខណ្ឌ/ក្រុង ................. ខេត្ត/រាជធានី............. កាលពីថ្ងៃទី..... ខែ...... ឆ្នាំ........ តាមបញ្ញត្តិមាត្រា......... នៃច្បាប់ស្តីពី........។

- បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលេខ............... ចុះថ្ងៃទី..... ខែ.....ឆ្នាំ.......។

**បង្គាប់**

១. ឱ្យភ្នាក់ងារមានសមត្ថកិច្ចនៃកម្លាំងសាធារណៈ ធ្វើការឃុំខ្លួនជនត្រូវចោទ ឈ្មោះ ................ ភេទ......... អាយុ......... ឆ្នាំ ជនជាតិ........... ទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួន.......... ដោយអនុវត្តត្រឹមត្រូវតាមច្បាប់។

២. ឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន........... ទទួល និងឃុំខ្លួនជននេះរហូតដល់មានបទបញ្ជាថ្មីសម្រេចផ្សេងពីនេះ ។

៣. ឱ្យគ្រប់ភ្នាក់ងារនៃកងកម្លាំងសាធារណៈទាំងអស់សហការអនុវត្តឱ្យបានល្អ នៅពេលដីកានេះត្រូវបានបង្ហាញក្នុងករណីចាំបាច់ ។

ថ្ងៃ.................... ខែ........ ឆ្នាំ......... ឯកស័ក ព.ស ............

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ........ ឆ្នាំ............

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

Logo

ឧបសម្ព័ន្ធទី ៧

សាលាដំបូងខេត្ត-រាជធានី
សំណុំរឿងព្រហ្មទណ្ឌលេខ..........
ចុះថ្ងៃទី....................................
សំណុំរឿងស៊ើបសួរលេខ.............
ចុះថ្ងៃទី....................................

## ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន

យើង........................ ចៅក្រមស៊ើបសួរនៃសាលាដំបូង.................. អមដោយ............... ជាក្រឡាបញ្ជី ។

- បានឃើញមាត្រា ២០៣ ដល់មាត្រា ២០៦ និងមាត្រាផ្សេងៗទៀត នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលទាក់ទងទៅនឹងការឃុំខ្លួនបណ្ដោះអាសន្ន

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ........... ចុះថ្ងៃទី..... ខែ..... ឆ្នាំ......... ដែលបានបើកការស៊ើបសួរលើ៖

ឈ្មោះ................. ឈ្មោះហៅក្រៅ................. ភេទ...... ថ្ងៃខែឆ្នាំកំណើត............... សញ្ជាតិ........... មុខរបរ.............. មានអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែនលេខ.................... កម្រិតវប្បធម៌..................... ទីកន្លែងកំណើតនៅភូមិ.....................ឃុំ/សង្កាត់..................... ស្រុក/ខណ្ឌ/ក្រុង................. ខេត្ត/រាជធានី........................។ ទីលំនៅផ្ទះលេខ........... ផ្លូវលេខ......... ភូមិ................. ឃុំ/សង្កាត់................ ស្រុក/ខណ្ឌ/ក្រុង.............. ខេត្ត/រាជធានី........................។

ឪពុកឈ្មោះ......................... រ☐ ស☐ ម្ដាយឈ្មោះ......................... រ☐ ស☐

ប្ដី/ប្រពន្ធឈ្មោះ.................រ☐ ស☐ មានកូន........នាក់ ឬនៅលីវ☐ នីតិជន☐ អនីតិជន☐ ។

មុខរបរ..................................... ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ.....................................។

ជននេះត្រូវបានដាក់នៅក្រោមការពិនិត្យពីបទ.......................... តាមមាត្រា.............................. នៃក្រមព្រហ្មទណ្ឌ/ច្បាប់..........................................................................................។

ប្រព្រឹត្តនៅផ្ទះលេខ........ ផ្លូវលេខ......... ភូមិ.....................ឃុំ/សង្កាត់..................... ស្រុក/ខណ្ឌ/ក្រុង................ ខេត្ត/រាជធានី....................... កាលពីថ្ងៃទី......... ខែ.......... ឆ្នាំ............។

បានឃើញកំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

បានឃើញកំណត់ហេតុស្តីពីការពិភាក្សាដេញដោល និងការកត់សម្គាល់របស់ភាគី

## I. ស្ថានភាពអង្គហេតុ និងអង្គច្បាប់

១. ក្នុងករណីបច្ចុប្បន្ន ជនត្រូវចោទឈ្មោះ ................... ត្រូវចោទពីបទ ............................(បញ្ចូលបទល្មើសដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ .............)

២. ប្រព្រឹត្តនៅ.......................................................................................................... (សង្ខេបអង្គហេតុនៃរឿង)

៣. តំណាងអយ្យការ បានស្នើឱ្យឃុំខ្លួន ☐ មិនឱ្យឃុំខ្លួន☐ បណ្តោះអាសន្នលើជនត្រូវចោទ

ឈ្មោះ........................... ផ្អែកលើសំអាងហេតុដូចតទៅ.............................................

..........................................................................................................................

.........................................................................................................

៤. ជនត្រូវចោទឈ្មោះ.......... ឬមេធាវីការពារ ស្នើសុំ (កូនក្តីឱ្យ) នៅក្រៅឃុំបណ្តោះអាន្ន☐ ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ☐ ដោយសំអាងហេតុថា

..........................................................................................................................

....................................................................................................។

## II. សំអាងហេតុនៃសេចក្តីសម្រេច

៥. ជនត្រូវចោទឈ្មោះ........................... ត្រូវចោទពីបទឧក្រិដ្ឋ/មជ្ឈិម ដែលច្បាប់កំណត់ដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ (មាត្រា២០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

៦. (បញ្ចូលនូវការយល់ឃើញឆ្លើយតបទៅនឹងសំអាងហេតុនានា ដែលលើកឡើងដោយភាគីមានដូចជា តំណាងអយ្យការ និងជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ ដោយពន្យល់សំអាងហេតុគាំទ្រទៅនឹងមូលហេតុនៃការឃុំខ្លួន ចំនួនមួយ ឬច្រើន ដែលចែងក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្ម

ទណ្ឌ)..................................................................................................................................
.(ហេតុផលជាមូលដ្ឋានពីថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន និងមានយោងតាមបញ្ញត្តិច្បាប់)........
.................................................................................................................................. ។

ដោយសារមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹង និងអាចធានាឱ្យមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះ ហើយមានតែការឃុំខ្លួនដែលជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចនូវគោលដៅខាងលើ។

## ហេតុដូច្នេះ សម្រេច

ឃុំខ្លួនជនត្រូវចោទឈ្មោះ............................. ជាបណ្ដោះអាសន្នរយៈពេលអតិបរមា .........។

ធ្វើនៅថ្ងៃ....... ខែ........ ឆ្នាំ......... ឯកស័ក ព.ស ............

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ........ ឆ្នាំ............

**ចៅក្រមស៊ើបសួរ**

**ឧបសម្ព័ន្ធទី ៨**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

...........

សាលាដំបូង...............

លេខ.....................................

## ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

យើង................................ ចៅក្រមស៊ើបសួរនៃសាលាដំបូង..................

អមដោយលោក/លោកស្រី.............................. ជាក្រឡាបញ្ជី ។

- បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

- បានឃើញមាត្រា ២០៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ........... ចុះថ្ងៃទី..... ខែ..... ឆ្នាំ......... របស់សាលាដំបូង..............។

- បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ........... ចុះថ្ងៃទី..... ខែ..... ឆ្នាំ......... របស់អយ្យការអមសាលាដំបូង......................។

- បានឃើញកំណត់ហេតុសួរចម្លើយជនត្រូវចោទ និងពិចារណាយ៉ាងត្រឹមត្រូវតាមច្បាប់រួចហើយ ។

**ហេតុដូច្នេះ សម្រេច**

១. មិនឃុំខ្លួនឈ្មោះ ...................... ភេទ......... អាយុ......... ឆ្នាំ ជនជាតិ............ ទីកន្លែងកំណើតនៅភូមិ.....................ឃុំ/សង្កាត់..................... ស្រុក/ខណ្ឌ/ក្រុង................. ខេត្ត/រាជធានី.........................ទីលំបច្ចុប្បន្ននៅផ្ទះលេខ........ ផ្លូវលេខ......... ភូមិ.................ឃុំ/សង្កាត់ ..................... ស្រុក/ខណ្ឌ/ក្រុង.............. ខេត្ត/រាជធានី.........................

ឪពុកឈ្មោះ......................... រ☐ ស☐ ម្ដាយឈ្មោះ......................... រ☐ ស ☐

ប្តី/ប្រពន្ធឈ្មោះ ....................រ☐ ស☐ មានកូន........នាក់ ឬនៅលីវ ☐ នីតិជន ☐ អនីតិជន ☐

ទោសពីមុន..........។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖.............................................. ប្រព្រឹត្តនៅ ចំណុច............. ផ្លូវលេខ....... ភូមិ..........ឃុំ/សង្កាត់............... ស្រុក/ខណ្ឌ/ក្រុង................. ខេត្ត/ រាជធានី............. កាលពីថ្ងៃទី...... ខែ........ ឆ្នាំ...........។ បទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទា ទោសតាមបញ្ញត្តិមាត្រា ............. នៃ......................។

២. សេចក្តីសម្រេចនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**<u>បានទទួលដំណឹងរួចហើយ</u>** នៅថ្ងៃ.... ខែ..... ឆ្នាំ...... ឯកស័ក ព .ស ........

ធ្វើនៅថ្ងៃ.... ខែ...... ឆ្នាំ..... ឯកស័ក ព.ស ........ រាជធានីភ្នំពេញ ថ្ងៃទី.....ខែ........ ឆ្នាំ ...........

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ........ ឆ្នាំ............ **ចៅក្រមស៊ើបសួរ**

**តំណាងអយ្យការ** **ក្រឡាបញ្ជី**

**ឧបសម្ព័ន្ធទី ៩**

Logo

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

សាលាដំបូង...................

លេខ......................................

**<u>ដីកាបង្គាប់ឱ្យដោះលែង</u>**

យើង................................... ចៅក្រមស៊ើបសួរនៃសាលាដំបូង.....................................

បានឃើញ ដីកាសម្រេចលើកលែងចោទប្រកាន់ ឬដីកាសម្រេចអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្នលេខ.............................. ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ............. របស់ចៅក្រមស៊ើបសួរនៃតុលាការខេត្ត-ក្រុង.................................. ដែលបានសម្រេច៖

.....................................................................................................................................

.....................................................................................................................................

បង្គាប់មកលោកប្រធានមន្ទីរឃុំខ្លួន .................................... ឱ្យដោះលែងជាបន្ទាន់ឈ្មោះ...................... ភេទ............ អាយុ .............ឆ្នាំ ជាតិ............. របររកស៊ី...................................
ទីលំនៅមុនពេលឃុំខ្លួននៅភូមិ................. ឃុំ-សង្កាត់........................ ស្រុក-ខណ្ឌ.....................
ខេត្ត-រាជធានី........................ ឃុំខ្លួនតាមដីកាលេខ.................. ចុះថ្ងៃទី......... ខែ............ ឆ្នាំ..... ប្រសិនបើឈ្មោះនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ។

នៅថ្ងៃ....... ខែ........ ឆ្នាំ......... ឯកស័ក ព.ស ..........

បានទទួលដំណឹងរួចហើយ

នៅថ្ងៃទី..... ខែ...... ឆ្នាំ.........

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ........ ឆ្នាំ

**ព្រះរាជអាជ្ញា**

**ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី ១០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រគល់សិទ្ធិតំណាង

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ............ ភេទ......... អាយុ .......ឆ្នាំ សញ្ជាតិ........ ដែលមានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ........ ផ្លូវ........... សង្កាត់................ ខណ្ឌ........... រាជធានីភ្នំពេញ ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ........... ចុះថ្ងៃទី...... ខែ..... ឆ្នាំ២០២... របស់សាលាដំបូង............ ។

## សូមប្រគល់សិទ្ធិជូន

មេធាវី ................. អត្តលេខ............ និងមេធាវី .............. អត្តលេខ............. ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃ ក្រុមហ៊ុនមេធាវី .......................... ដែលមានការិយាល័យស្ថិតនៅអគារ........ ជាន់ទី....... ផ្លូវលេខ........ សង្កាត់......... ខណ្ឌ.......... រាជធានីភ្នំពេញ ធ្វើជាមេធាវីមេធាវីតំណាងឱ្យខ្ញុំបាទ/នាងខ្ញុំដែលជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ........... ចុះថ្ងៃទី...... ខែ..... ឆ្នាំ២០២... របស់សាលាដំបូង............ ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ។

ធ្វើនៅ.......... ថ្ងៃទី..... ខែ....... ឆ្នាំ២០២..

**ស្នាមមេដៃស្តាំ**

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែ........ ឆ្នាំ២០២..

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី ១១

## ពាក្យសុំពឹងពាក់មេធាវី

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ............. ភេទ..... អាយុ ...... ឆ្នាំ សញ្ជាតិ..... មានទីលំនៅផ្ទះលេខ..... ផ្លូវលេខ ......... សង្កាត់......... ខណ្ឌ........... រាជធានីភ្នំពេញ។

## សូមពឹងពាក់

លោកមេធាវី ............ អត្តលេខ........ និងលោកមេធាវី ......... អត្តលេខ........ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃក្រុមហ៊ុន................ មានអាសយដ្ឋាននៅអគារ ........... ជាន់ទី....... ផ្លូវលេខ......... សង្កាត់......... ខណ្ឌ.......... រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីការពារក្តីឱ្យខ្ញុំបាទនៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ........... ចុះថ្ងៃទី....... ខែ........ ឆ្នាំ ២០២.... របស់សាលាដំបូង.............. នៅក្នុងនីតិវិធីទាំងមូល ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ។

លោកមេធាវីការពារក្តី មានសិទ្ធិអនុវត្តកិច្ចការតាមច្បាប់ ដែលខ្ញុំបាទ/នាងខ្ញុំ បានពឹងពាក់ដូចបានបញ្ជាក់ខាងលើចាប់ពីកាលបរិច្ឆេទចុះហត្ថលេខា-ផ្តិតមេដៃនេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី..... ខែ...... ឆ្នាំ ២០២...

ហត្ថលេខា/ស្នាមមេដៃអ្នកសុំពឹងពាក់

បានឃើញ និងយល់ព្រម

ធ្វើជាមេធាវីការពារក្តីទៅតាមនីតិវិធីច្បាប់។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...... ខែ...... ឆ្នាំ២០២...